# របាយការណ៍ស្តីពីសិទ្ធិមនុស្ស ឆ្នាំ ២០១៤

## សេចក្តីសង្ខេបរួម

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលមានរដ្ឋាភិបាលមួយកើតចេញតាមរយៈការបោះឆ្នោតសភា ។ នៅក្នុងការបោះឆ្នោតកាលពីពេលថ្មីៗបំផុតនេះ ដែលរៀបចំធ្វើឡើងនៅខែកក្កដា ឆ្នាំ ២០១៣ គណបក្សប្រជាជនកម្ពុជា (CPP) បានឈ្នះអាសនៈភាគច្រើន ក្នុងចំណោមអាសនៈរដ្ឋសភាចំនួន១២៣ អាសនៈ ។ អ្នកសង្កេតការណ៍អន្តរជាតិ និងអ្នកសង្កេតការមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានវាយតម្លៃថា ដំណើរការបោះឆ្នោតនេះមានប្រការខុសឆ្គងជាច្រើន ដែលរួមមានបញ្ហាបញ្ជីអ្នកបោះឆ្នោត លទ្ធភាពមិនស្មើគ្នាក្នុងការទទួលបានការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា និងការចេញប័ណ្ណអ្នកបោះឆ្នោតផ្លូវការបណ្តោះអាសន្នយ៉ាងច្រើនខុសធម្មតាអោយអ្នកបោះឆ្នោត។ អាជ្ញាធររក្សាប់ណែនលើកំលាំងសន្តិសុខ។

បញ្ហាបីធំជាងគេផ្នែកសិទ្ធិមនុស្សគឺការផ្អាកតាមអំពើចិត្តនូវសិទ្ធិក្នុងការធ្វើការប្រមូលផ្តុំគ្នា នៅក្នុងទីក្រុង ប្រព័ន្ធតុលាការគ្មានប្រសិទ្ធភាព និងមានលក្ខណៈនយោបាយ ហើយនិងការរឹតត្បិតលើសេរីភាពសារព័ត៌មាន។

បញ្ហាផ្នែកសិទ្ធិមនុស្សដទៃទៀតរួមមានការបន្តរំលោភធ្វើបាបអ្នកទោស អំពើពុករលួយនៅគ្រប់កន្លែង ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាលគ្មានប្រសិទ្ធភាព និងការជួញដូរមនុស្ស។

រដ្ឋាភិបាលបានកាត់ទោសមន្ត្រីខ្លះដែលបានប្រព្រឹត្តបទរំលោភ តែនិទណ្ឌភាពចំពោះអំពើពុករលួយ និងបទរំលោភភាគច្រើននៅតែមាន។

### ផ្នែកទី១ ៖ ការគោរពភាពថ្លៃថ្នូររបស់មនុស្ស រួមទាំងសេរីភាពរួចផុតពី ៖

### ក. ការដកហូតជីវិតតាមអំពើចិត្ត ឬដោយខុសច្បាប់

មានរបាយការណ៍តាមសារព័ត៌មាននៅថ្ងៃទី ៣ ខែមករាថា កងកម្លាំងសន្តិសុខរបស់រដ្ឋាភិបាលបានបាញ់សំលាប់អ្នកធ្វើការតវ៉ាចំនួន ៤ នាក់ ហើយបានធ្វើអោយរបួសដល់ជាង ៣៥ នាក់ទៀត នៅភ្នំពេញនៅក្នុងអំឡុងពេលមានការប៉ះទង្គិចគ្នា ដែលកើតចេញពីការតវ៉ារបស់កម្មកររោងចក្រកាត់ដេរ ដែលទាមទារ

អោយដំឡើងប្រាក់ខែអប្បបរិមា នៅក្រៅរោងចក្រកាត់ដេរកាណាឌីយ៉ា តាមផ្លូវវែងស្រែង ជិតរាជធានីភ្នំពេញ។ រដ្ឋាភិបាលបានបើកការស៊ើបអង្កេត ដែលរហូតដល់ខែសីហា នៅតែបន្តធ្វើនៅឡើយ។

នៅថ្ងៃទី ២៦ ខែមករា ពឿន ប៉ា ដែលជាទាហានក្នុងកងពលតូចលេខ ៤១ នៅខេត្តព្រះវិហារ បានបាញ់សំលាប់ឈ្មោះ ទ្រី ចំរើន នៅស្រុកគូលែន នៃខេត្តព្រះវិហារ នៅក្នុងពេលមានការប្រតាយប្រតប់គ្នា បន្ទាប់ពីទាហាននោះបានចោទប្រកាន់អ្នកភូមិមួយក្រុមថា បានដាំដំណាំនៅលើដីរបស់មេរបស់ខ្លួន។ នគរបាលបានចាប់ឃុំខ្លួនឈ្មោះពឿន ដោយរង់ចាំសវនាការ។

ខ្មែរអ្នកកាប់ឈើខុសច្បាប់ឆ្លងកាត់ព្រំដែនបានប៉ះទង្គិចគ្នាជាមួយកំលាំងសន្តិសុខថៃនៅក្នុងឆ្នាំនៃរបាយការណ៍នេះ។ យោងតាមអង្គការមិនមែនរដ្ឋាភិបាលខ្មែរមួយ កំលាំងសន្តិសុខថៃបានសំលាប់ពលរដ្ឋខ្មែរចំនួន ១៩ នាក់ នៅក្នុងឧប្បត្តិហេតុចំនួន ៦ ដាច់ដោយឡែកពីគ្នា ដោយគិតត្រឹមខែកក្កដា។ រដ្ឋាភិបាលកម្ពុជាបានខិតខំបញ្ឈប់ពលរដ្ឋខ្លួនមិនអោយធ្វើសកម្មភាពបែបនេះ ហើយបានសុំអោយរដ្ឋាភិបាលថៃធ្វើការស៊ើបអង្កេត និងបញ្ឈប់ការសំលាប់ក្រៅប្រព័ន្ធតុលាការ

## ខ. ការបាត់ខ្លួន

អង្គការមិនមែនរដ្ឋាភិបាលខ្មែរមួយបានរាយការណ៍ថា ឈ្មោះ ខែម សុផាត អាយុ ១៧ ឆ្នាំ បានបាត់ខ្លួន បន្ទាប់ពីកំលាំងសន្តិសុខរដ្ឋាភិបាលត្រូវបានគេនិយាយថា បានបាញ់គាត់ នៅក្នុងពេលមានការប៉ះទង្គិចគ្នាដោយហឹង្សា នៅក្រៅរោងចក្រកាត់ដេរកាណាឌីយ៉ា តាមផ្លូវវែងស្រែង។ សាក្សីបានឃើញគាត់ត្រូវបានគេដាក់ចូលទៅក្នុងឡានពេទ្យមួយ។ គិតរហូតដល់ខែសីហា ឈ្មោះនេះនៅតែបាត់ខ្លួននៅឡើយ។ រដ្ឋាភិបាលមិនបានឆ្លើយតបនឹងលិខិតសួរនាំរបស់គណកម្មាធិការស្តីពីការបាត់ខ្លួនដោយបង្ខំ របស់អង្គការសហប្រជាជាតិ និងការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សទេ។

## គ. ការធ្វើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មបន្ទាបបន្ថោក អមនុស្សធម៌ ឬឃោរឃៅដទៃទៀត

រដ្ឋធម្មនុញ្ញហាមប្រាមទង្វើបែបនេះ តែការវាយតប់ និងទំរង់ដទៃទៀតនៃការធ្វើបាបលើរូបរាងកាយទៅលើអ្នកជាប់ឃុំរបស់នគរបាល និងអ្នកជាប់ពន្ធនាគារនៅតែមានជាបន្ត ដោយតាមសេចក្តីរាយការណ៍មកមានចំនួនកាន់តែច្រើនឡើង បើប្រៀបធៀបនឹងឆ្នាំ ២០១៣។

មានរបាយការណ៍ដែលអាចទុកចិត្តបានថា មន្ត្រីកងរាជអាវុធហត្ថ និងនគរបាលស៊ីវិលបានធ្វើទារុណកម្មលើរាងកាយ និងផ្លូវចិត្ត ហើយមានពេលខ្លះ វាយដំយ៉ាងធ្ងន់ធ្ងរទៅលើជនដែលត្រូវឃុំខ្លួនដោយសារបទព្រហ្មទណ្ឌទៀតផង ជាពិសេសនៅអំឡុងពេលសួរចម្លើយ ។ គិតមកដល់ខែមិថុនា អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា អាជ្ញាធរបានរំលោភធ្វើបាបអ្នកជាប់ពន្ធនាគារចំនួនយ៉ាងហោចណាស់ ៦២ នាក់ នៅក្រោមការឃុំខ្លួនរបស់នគរបាល ។ ការទាត់ធាក់ ការដាល់ និងការវាយវាត់ដោយកាំភ្លើងខ្លីគឺជាវិធីរំលោភបំពានលើរូបរាងកាយដែលតាមសេចក្តីរាយការណ៍មកថាបានកើតមានឡើងច្រើនជាងគេ ។ តែអាជ្ញាធរក៏បានប្រើផងដែរនូវការឆក់ខ្សែភ្លើង ការធ្វើអោយថប់ដង្ហើម និងការវាយនឹងខ្សែភ្លើង ។ អង្គការ NGO នានាបានរាយការណ៍ថា ជារឿងធម្មតា ដែលនគរបាលធ្វើទារុណកម្មលើជនសង្ស័យ ដែលត្រូវឃុំខ្លួនរហូតទាល់តែអ្នកទាំងនេះសារភាពថាបានប្រព្រឹត្តកំហុស ។ តុលាការយកសេចក្តីសារភាពដោយបង្ខំធ្វើជាភស្តុតាងស្របច្បាប់នៅអំឡុងពេលជំនុំជម្រះក្តី ទោះបីជាច្បាប់ហាមមិនអោយយកជាការបានក្តី ។

ក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំរបាយការណ៍នេះ អង្គការមិនមែនរដ្ឋាភិបាលខ្មែរផ្នែកសិទ្ធិមនុស្ស ដែលមានឈ្មោះថា អាដហុក បានរាយការណ៍ពីករណីចំនួន ១២ ដែលក្នុងនោះ អាជ្ញាធរមូលដ្ឋាន ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សឯកជនរបស់មន្ត្រីរដ្ឋាភិបាលបានប្រើកំលាំងទៅលើជនស៊ីវិល។ បើប្រៀបធៀបនឹងឆមាសទី១ នៃឆ្នាំ ២០១៣ ដែលមាន ២៦ ករណីត្រូវបានរាយការណ៍មក។ ក្នុងករណីខ្លះ នគរបាលបានប្រើកំលាំងដើម្បីទប់ទល់នឹងការគំរាមប្រើហឹង្សា ឬអំពើហឹង្សារបស់អ្នកធ្វើបាតុកម្ម។ ក្នុងករណីខ្លះទៀត នគរបាលបានប្រើកំលាំងប្រឆាំងនឹងអ្នកធ្វើបាតុកម្មអហឹង្សា បន្ទាប់ពីអ្នកធ្វើបាតុកម្មធ្វើអោយរំខានដល់ចរាចរតាមផ្លូវ ហើយមិនព្រមបំបែកគ្នាតាមការបញ្ជា។

ចំនួនមជ្ឈមណ្ឌលបន្សាបគ្រឿងញៀនរបស់រដ្ឋាភិបាលបានកើនពីចំនួន ៧ ដល់ ១០។ អ្នកសង្កេតការភាគច្រើនបានយល់ស្របថា ភាគច្រើននៃអ្នកដែលត្រូវបានយកមកឃុំនៅទីនេះគឺត្រូវបានឃុំដោយបង្ខំ ឬផ្ញើនៅមណ្ឌល ដោយសមត្ថកិច្ច ឬសមាជិកគ្រួសារ។ យោងតាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គ្មានអ្នកត្រូវឃុំដែលមានអាយុក្រោម ១៨ ឆ្នាំទេ។ អ្នកសង្កេតការបានកត់សំគាល់ឃើញថាបុគ្គលិកក្នុងមណ្ឌល ជាញឹកញាប់ ប្រើវិធីបង្ខំ ដើម្បី “គ្រប់គ្រង”ទៅលើអ្នកជាប់ក្នុងនោះ ដូចជាបង្ខាំងពួកគេ ឬអោយហាត់ប្រាណយ៉ាងខ្លាំង ឬប្រើវិធីក្តៅដៃទៀត។ ថ្នាក់ដឹកនាំរដ្ឋាភិបាលបានទទួលស្គាល់សារៈសំខាន់នៃការព្យាបាលការញៀនថ្នាំថា ជារឿងសុខភាព ជាជាងរឿងព្រហ្មទណ្ឌ តែគ្មានចាត់វិធានការច្រើនតាមការនិយាយនោះទេ។

**ស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំខ្លួន**

ស្ថានភាពពន្ធនាគារមិនសមស្របតាមបទដ្ឋានអន្តរជាតិឡើយ ។ ស្ថានភាពនៅតែមាន លក្ខណៈយ៉ាប់ និងពេលខ្លះ គម្រាមកំហែងដល់អាយុជីវិតទៀតផង ។ អង្គការសិទ្ធិមនុស្សនានាបានលើកឡើងពីបញ្ហាធ្ងន់ធ្ងរមួយចំនួន រួមមានដូចជាស្ថានភាពចង្អៀតណែនខ្លាំងពេក បញ្ហាសុខភាព ព្រមទាំងអនាម័យបរិស្ថាន កង្វះអាហារ និងទឹក កង្វះអាហារូបត្ថម្ភ និងសន្តិសុខមិនល្អ ។

<u>ទិដ្ឋភាពទីកន្លែង៖</u> យោងតាមនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ដោយគិតត្រឹមខែមិថុនា មានអ្នកទោស និងអ្នកជាប់ពន្ធនាគារចំនួន ១៤ ៦២០ នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ១ ១០៣ នាក់ និងកុមារចំនួន ៣២២ នាក់ ។ មានពន្ធនាគារចំនួន ២៧ នៅទូទាំងប្រទេស ដែលបានបង្កើតឡើងដើម្បីដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំរហូតដល់ ១១ ០០០ នាក់ ។

នៅក្នុងពន្ធនាគារភាគច្រើន គ្មានការដាក់អោយនៅដាច់ពីគ្នាទេរវាងអ្នកទោសជាមនុស្សពេញវ័យ និងអ្នកទោសជាកុមារ រវាងប្រុស និងស្រី ឬរវាងអ្នកទោសធ្ងន់ និងអ្នកទោសស្រាលទេ។ ជាធម្មតា អាជ្ញាធរដាក់អ្នកជាប់ឃុំដែលមិនទាន់បានកាត់ក្តី និងអ្នកដែលត្រូវបានតុលាការកាត់ក្តីហើយ អោយនៅឡូកឡំគ្នា។ បើយោងតាមស្ថិតិរបស់រដ្ឋាភិបាល ដោយគិតមកត្រឹមខែមិថុនា មនុស្សប្រមាណ ២៤% នៅក្នុងពន្ធនាគារតាមខេត្ត ក្រុងមិនទាន់ត្រូវបានតុលាការកាត់ទោសនៅឡើយទេ។

នាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា ដោយគិតមកត្រឹមខែមិថុនា មានអ្នកជាប់ពន្ធនាគារចំនួន ៣០ នាក់បានស្លាប់ក្នុងពន្ធនាគារ។ នគរបាលបានអះអាងថា គេបានធ្វើការស៊ើបអង្កេត ហើយបានរកឃើញថា ការស្លាប់គឺបណ្តាលមកពីការមានជំងឺពីមុនមក ឬជំងឺដទៃទៀត ។

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានអះអាងថា របបអាហារសម្រាប់អ្នកជាប់ពន្ធនាគារ និងរបស់ចាំបាច់ផ្សេងៗទៀត តែនៅតែមិនគ្រប់គ្រាន់ទេ។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា របបសំរាប់ទិញអាហារសំរាប់អ្នកទោស ពេលខ្លះ ត្រូវបានកិបកេងយក ដែលជាធ្វើអោយកង្វះអាហារូបត្ថម្ភ និងជំងឺរបស់អ្នកទោសមានកាន់តែច្រើន។ អ្នកទោសមានទឹកស្អាតប្រើប្រាស់នៅតាមពន្ធនាគារខ្លះ។ ពន្ធនាគារគ្មានកន្លែងគ្រប់គ្រាន់សំរាប់អ្នកមានជំងឺខួរក្បាល (ជំងឺសតិ) និងអ្នកពិការ។ អង្គការមិនមែនរដ្ឋាភិបាល (NGO) បានរាយការណ៍ផងដែរថា អ្នកទោសដែលគ្រួសាររបស់គេសូកអ្នកគ្រប់គ្រងពន្ធនាគារ មានស្ថានភាពគ្រាន់បើ ដូចជាអាចជួបជាមួយអ្នកទៅសួរសុខទុក្ខ ត្រូវបានផ្ទេរទៅកន្លែងល្អ ហើយអាចចេញពីបន្ទប់ឃុំ នៅពេលថ្ងៃ។

<u>**រដ្ឋបាល**៖</u> មានការធ្វើកំណត់ហេតុគ្រប់គ្រាន់ស្តីពីអ្នកទោស។ អាជ្ញាធរមិនបានប្រើវិធីផ្សេងក្រៅពីការដាក់គុកទេ សំរាប់ជនល្មើសអហឹង្សា។ ការធានាអោយនៅក្រៅឃុំមិនសូវមានគេអនុវត្តទេ ហើយ អាជ្ញាធរមិន

បានអនុវត្តប្រព័ន្ធនៃការដោះលែងដោយមានលក្ខខ័ណ្ឌមុនកំណត់ត្រូវដោះលែង (Parole system) ដូចដែលត្រូវបានអនុញ្ញាតនៅក្នុងក្រមនិតិវិធីព្រហ្មទណ្ឌទេ។ អង្គការមិនមែនរដ្ឋាភិបាលខ្មែរមួយបានសង្កេតឃើញថារដ្ឋាភិបាលខ្វះធនធានថវិកា និងធនធានមនុស្សសំរាប់អនុវត្តកម្មវិធីបែបនេះ។ គ្មានបទបញ្ញាតិដែលកំណត់អោយមានមន្ត្រីសំរាប់ធ្វើការស៊ើបអង្កេតទាក់ទងនឹងបណ្តឹងរបស់ពលរដ្ឋប្រឆាំងនឹងផ្នែកពន្ធនាគារទេ ។ អ្នកទោស និងអ្នកជាប់ការឃុំឃាំងជាធម្មតាត្រូវបានអនុញ្ញាតអោយជួបជាមួយអ្នកទៅមើល តែអង្គការសិទ្ធិមនុស្សបានអះអាងថា ពេលខ្លះ គ្រួសារត្រូវផ្តល់សំណូកដល់មន្ត្រីពន្ធនាគារដើម្បីបានសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ឬត្រូវផ្តល់ស្បៀងអាហារ និងរបស់របរចាំបាច់ដទៃទៀត ។

មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា ជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូក មុននឹងអនុញ្ញាតអោយអ្នកជាប់ពន្ធនាគារចូលរួមការជំនុំជម្រះក្តី ឬសវនាការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារដែលបានបញ្ចប់អាណត្តិជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ។

អ្នកទោស និងអ្នកជាប់ឃុំត្រូវបានអនុញ្ញាតអោយគោរពសាសនារបស់គេ។

អ្នកទោសអាចដាក់បណ្តឹងស្តីពីការរំលោភបំពានទៅតុលាការ តាមរយៈមេធាវី ដោយមិនមានការត្រួតពិនិត្យកែប្រែឡើយ។ តែអ្នកទោសមួយចំនួនធំគ្មានលទ្ធភាពរកមេធាវីតំណាងផ្លូវច្បាប់ឡើយ។ រដ្ឋាភិបាលស៊ើបអង្កេតលើពាក្យបណ្តឹងបែបនេះ ហើយតាមមើលស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំឃាំងតាមរយៈអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ដែលធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ សាធារណជនអាចមើលរបាយការណ៍ទាំងនេះ និងរបាយការណ៍ស៊ើបអង្កេតដទៃទៀតបានបើគេស្នើសុំ។

<u>ការតាមដានដោយឯករាជ្យ៖</u>ជាទូទៅ រដ្ឋាភិបាលបានអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្រុមសិទ្ធិមនុស្សក្នុងស្រុក ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា ជួនកាល ការសហការពីអាជ្ញាធរដែនដីនៅមានកម្រិត ដែលជាការធ្វើអោយមានការលំបាកសម្រាប់ទាក់ទងអ្នកជាប់ឃុំដែលមិនទាន់ទទួលការជំនុំជម្រះក្តី ។ ក្រសួងមហាផ្ទៃតម្រូវអោយមេធាវី អ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាត មុននឹងចូលជួបអ្នកជាប់ពន្ធនាគារ ។ ក្នុងករណីខ្លះ មន្ត្រីនៅតែបន្តអនុញ្ញាតអោយអង្គការមិនមែនរដ្ឋាភិបាលធ្វើការសម្ភាសន៍អ្នកជាប់ពន្ធនាគារ ជាលក្ខណៈឯកជន ។ ចំណែកតំណាងអង្គការ

UNHCHR វិញបានរាយការណ៍មកថា ជាធម្មតា ខ្លួនអាចជួបជាលក្ខណៈឯកជននៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារពិសេសណាមួយ ។ អង្គការក្នុងស្រុកដែលធ្វើការតាមដានដោយឯករាជ្យ ធ្វើការដោយមានឯករាជ្យគ្រប់គ្រាន់ ដាច់ចេញពីឥទ្ធិពលរបស់រដ្ឋាភិបាល។

កំណែលំអៈ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលតាមដានស្ថានភាពពន្ធនាគារ បានរាយការណ៍ថា ថ្វីត្បិតតែគ្មានកំណែលំអគ្រប់គ្រាន់លើស្ថានភាពពន្ធនាគារក្តី តែមាននិន្នាការអនុគ្រោះលើចំនួនពេលដែលអ្នកជាប់ពន្ធនាគារត្រូវបានផ្តល់អោយនៅក្រៅបន្ទប់ឃុំឃាំងរបស់គេ និងការមានទឹកនិងអាហារស្អាតបរិភោគ។

## ឃ. ការចាប់ខ្លួន ឬការឃុំខ្លួនដោយបំពាន

ច្បាប់ហាមឃាត់ការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន ទោះជាយ៉ាងណាក៏ដោយ មានពេលខ្លះរដ្ឋាភិបាលមិនគោរពបម្រាមទាំងនេះឡើយ ។

## តួនាទីរបស់នគរបាល និងក្បាលម៉ាស៊ីនសន្តិសុខ

អគ្គស្នងការនគរបាលជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ គ្រប់គ្រងអង្គភាពនគរបាលស៊ីវិលទាំងអស់ ។ កម្លាំងនគរបាលត្រូវបែងចែកជាកម្លាំងដែលមានអំណាចធ្វើការចាប់ខ្លួន កម្លាំងដែលគ្មានអំណាចចាប់ខ្លួន និងនគរបាលយុត្តិធម៌ ។ កងរាជអាវុធហត្ថទទួលបានការអនុញ្ញាតអោយចាប់ខ្លួនជនស៊ីវិល ប្រសិនបើមន្ត្រីទាំងនោះបំពេញលក្ខខ័ណ្ឌក្នុងការបណ្តុះបណ្តាល និងបទពិសោធន៍ក្នុងការបំពេញការងារជានគរបាលស៊ីវិល ប្រសិនបើជនស៊ីវិលស្ថិតនៅកន្លែងរបស់យោធា ឬក្នុងករណីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។ តែតាមភាពជាក់ស្តែង កងរាជអាវុធហត្ថធ្វើសកម្មភាពលើជនស៊ីវិលជាធម្មតា ក្រោមការអនុញ្ញាតនិងចង្អុលរបស់អាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន ដោយជាញឹកញាប់ ដើម្បីជួយនគរបាលផ្នែកស៊ីវិលដែលមិនអាចទប់ទល់នឹងហ្វូងមនុស្សដោយខ្លួនឯងបាន។ ក្រសួងមហាផ្ទៃគឺជាស្ថាប័នសំខាន់ដែលជាអ្នកត្រូវធ្វើការវាយតំលៃការសំលាប់ដោយកំលាំងសន្តិសុខ។

មន្ត្រីនគរបាលបានប្រព្រឹត្តអំពើរំលោភបំពានផ្សេងៗដោយមាននិទណ្ឌភាព(ភាពគ្មានទោស) ហើយក្នុងករណីភាគច្រើន អាជ្ញាធរបានចាត់វិធានការបន្តិចបន្តួច ឬពុំមានចាត់វិធានការអ្វីឡើយ ។ ច្បាប់តម្រូវអោយនគរបាល ព្រះរាជអាជ្ញា និងចៅក្រមធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ រួមទាំងបណ្តឹងអំពីការរំលោភបំពានរបស់នគរបាលផងដែរ ។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង ចៅក្រម និងព្រះរាជអាជ្ញាកម្រធ្វើការស៊ើបអង្កេតដោយឯករាជ្យ ដែលជាផ្នែកមួយនៃដំណើរការជំនុំជម្រះក្តីជាសាធារណៈ

ណាស់ ។ ចៅក្រមជំនុំជម្រះ ជាធម្មតា ចេញសាលក្រមផ្អែកតាមតែរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលទទួលបានមកពីនគរបាល និងសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ ។ ជាទូទៅ នគរបាលបានទទួលការបណ្តុះបណ្តាលជំនាញបន្តិចបន្តួចតែប៉ុណ្ណោះ ។ ទោះបីជាគ្មានសិទ្ធិអំណាចក្នុងការធ្វើការចាប់ខ្លួនក្តី តែកងរាជអាវុធហត្ថក្នុងអង្គភាពឆ័ត្រយោង ក្នុងកងពលតូចលេខ ៩១១ បានវាយនិងចាប់ខ្លួនអ្នកតវ៉ាចំនួន ១០ នាក់ ដោយទន្ទឹមនឹងនោះ បានបំបែកកម្មករដែលធ្វើការតវ៉ា នៅរោងចក្រ Yakjin ។ អ្នកតវ៉ាទាមទារអោយមានការដំឡើងប្រាក់ខែអប្បបរិមារបស់គេ។ នៅថ្ងៃបន្ទាប់ កំលាំងសន្តិសុខរបស់រដ្ឋាភិបាលបានចាប់ខ្លួនអ្នកតវ៉ាចំនួន ១៣ នាក់ថែមទៀត នៅក្នុងពេលមានការប៉ះទង្គិចគ្នាដោយហឹង្សាលើផ្លូវវេងស្រេង។ អ្នកតវ៉ាទាំង ២៣ នាក់ត្រូវបានបញ្ជូនទៅពន្ធនាគារក្នុងខេត្តកំពង់ចាម ដើម្បីឃុំមុនពេលចូលសវនាការ។ នៅថ្ងៃទី ៣០ ខែឧសភា តុលាការក្រុងភ្នំពេញបានដាក់ទោសអោយអ្នកទាំងនោះជាប់ទោសត្រឹមពេលដែលគេបានជាប់ឃុំកន្លងមក ហើយបានបញ្ជាអោយដោះលែងពួកគេ។

## នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តនៅពេលឃុំខ្លួន

ច្បាប់តម្រូវអោយនគរបាលសុំដីកាពីចៅក្រមស៊ើបអង្កេត មុនធ្វើការចាប់ខ្លួន ប៉ុន្តែនគរបាលអាចចាប់ខ្លួនដោយគ្មានដីកាចំពោះជនណាដែលត្រូវបានប្រទះឃើញកំពុងប្រព្រឹត្តបទល្មើស ។ ច្បាប់អនុញ្ញាតអោយនគរបាលឃាត់ខ្លួនបុគ្គលណាម្នាក់ រួចធ្វើការស៊ើបអង្កេតក្នុងរយៈពេល៤៨ម៉ោង ដោយមិនរាប់បញ្ចូលរយៈ ពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាកផ្លូវការ មុននឹងធ្វើការចោទប្រកាន់ ឬមុនពេលជនសង្ស័យត្រូវបានដោះលែង ។ ក្នុងករណីបទឧក្រិដ្ឋក្នុងស្ថាន ភាពពិសេសដែលចែងដោយច្បាប់ នគរបាលអាចឃុំខ្លួនជនសង្ស័យរយៈពេល ២៤ ម៉ោងបន្ថែម ដោយមានការឯកភាពពីព្រះរាជអាជ្ញា ។ ទោះជាយ៉ាងនេះក្តី ជាទម្លាប់អាជ្ញាធរតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់ មុនធ្វើការចោទប្រកាន់ ។ មានវិធីនៃការធានាអោយនៅក្រៅឃុំ តែអ្នកជាប់ពន្ធនាគារជាច្រើន ជាពិសេសអ្នកដែលគ្មានតំណាងផ្នែកច្បាប់ ឬមេធាវី គ្មានឱកាសស្វែងរកការដោះលែងដោយការធានាអោយ នៅក្រៅឃុំឡើយ ។ តាមក្រោមច្បាប់ ជនជាប់ចោទអាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរហូតដល់រយៈ ពេល ២៤ម៉ោង មុននឹងអាចមានលទ្ធភាពទទួលបានប្រឹក្សាច្បាប់ ប៉ុន្តែអ្នកជាប់ពន្ធនាគារជាធម្មតា ត្រូវជាប់ឃុំជាច្រើនថ្ងៃ មុននឹងគេទទួលបានមេធាវី ឬជួបសមាជិកគ្រួសារ ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរបែបនេះ ភាគច្រើនបណ្តាលមកពីសមត្ថភាពមានកម្រិតនៃប្រព័ន្ធតុលាការ ។

មេធាវីរបស់អ្នកតវ៉ាទាំង ២៣ នាក់ ដែលត្រូវបានចាប់ខ្លួន នៅថ្ងៃទី ២ និងទី ៣ ខែមករា ត្រូវបានអនុញ្ញាតអោយមានមេធាវី នៅក្នុងអំឡុងពេល ២៤ ម៉ោងនៃការចាប់ខ្លួនគេ ។ តែនៅពេលបន្ទាប់មក អ្នក

ជាប់ឃុំទាំងនោះត្រូវបានគេដឹកទៅកាន់កន្លែងឃុំឃាំង នៅក្នុងខេត្តកំពង់ចាម ដោយគ្មានអោយទាក់ទងជាមួយនរណាឡើយ រហូតដល់ថ្ងៃទី ៨ ខែមករា។

<u>ការចាប់ខ្លួនតាមអំពើចិត្តៈ</u> អង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមានឈ្មោះថា អាដហុកបាននិយាយថា មានករណីចាប់ខ្លួន ឬឃុំខ្លួនយ៉ាងតិចចំនួន ២២ ករណី ដែលគេចាត់ទុកថា ជាអំពើធ្វើតាមអំពើចិត្ត នៅត្រឹមខែមិថុនា តែមិនបានលើកឡើងនូវឧទាហរណ៍ច្បាស់ណាមួយទេ។ អង្គការអាដហុកបានថ្លែងថា ជនរងគ្រោះនៅក្នុងករណីឃុំខ្លួនតាមអំពើចិត្តចំនួន ១៦ ករណី ត្រូវបានដោះលែងវិញ នៅពេលក្រោយមក បន្ទាប់ពីជនជាប់ឃុំបានធ្វើការប្តឹង បន្ទាប់ពីមានអន្តរាគមពីអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស ឬការផ្តល់សំណូក។ ចំនួននៃការចាប់ខ្លួនតាមអំពើចិត្តទំនងជាមានច្រើនជាងនេះ ពីព្រោះជនរងគ្រោះនៅតាមតំបន់ជនបទមិនប្តឹង ដោយសារមានការពិបាកធ្វើដំណើរមកការិយាល័យរបស់អង្គការអាដហុក ឬមានកង្វល់ពីសុវត្ថិភាពនៃគ្រួសាររបស់គេ។ អាជ្ញាធរមិនបានចាត់វិធានដាក់ទណ្ឌកម្ម ឬវិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះការឃុំខ្លួនដោយខុសច្បាប់ទេ។

នៅក្នុងឆ្នាំនៃរបាយការណ៍នេះ អាជ្ញាធរក្រុងភ្នំពេញបានចាប់ខ្លួនមនុស្សរាប់សិបអ្នក ដែលជាធម្មតាគឺអ្នកគ្មានផ្ទះសម្បែង អ្នកវិកលចរិក អ្នកប្រើគ្រឿងញៀន ឬអ្នករកស៊ីផ្លូវភេទ  ក្នុងអំឡុងពេលយុទ្ធនាការចុះបោសសំអាត។ ជាធម្មតា អ្នកដែលត្រូវឃុំខ្លួនបាត់បង់លុយកាក់ និងទ្រព្យសម្បត្តិអស់ ក្នុងអំឡុងពេលនៃការបោសសំអាតនោះ។ តាមប្រភពពីអង្គការមិនមែនរដ្ឋាភិបាលមួយ អ្នកជាប់ឃុំច្រើនបាត់លុយ និងរបស់របរ នៅក្នុងពេលនៃការចុះបោសសំអាត ដែលអាជ្ញាធរហៅថា ជាផ្នែកមួយនៃការ “ធ្វើអោយសង្គមមានសណ្តាប់ធ្នាប់”។  អាជ្ញាធរយកអ្នកទាំងនោះទៅដាក់នៅមជ្ឈមណ្ឌលរបស់ក្រសួងសង្គមកិច្ច ដែលមានចំងាយ ១៥ ម៉ៃល៍ ពីក្រុងភ្នំពេញ យកទៅផ្ញើនឹងអង្គការ NGO ក្នុងស្រុក តែអ្នកដែលត្រូវបានយកទៅផ្ញើជាមួយ NGO ច្រើនតែត្រូវបានដោះលែងអោយមកនៅតាមផ្លូវវិញ តែក្នុងរយៈពេលប៉ុន្មានម៉ោងតែប៉ុណ្ណោះ។

នៅថ្ងៃទី ៦ ខែមិថុនា អាជ្ញាធរក្រុងភ្នំពេញបានចេញបទបញ្ជាមួយអោយប្រមូលកុមារតាមដងផ្លូវ អ្នកលក់ដូរ និងអ្នកដើរសុំទានយកទៅទុកនៅមជ្ឈមណ្ឌលថែទាំ។ ក្នុងពេលចុះប្រតិបត្តិការដើរប្រមូល អាជ្ញាធរបានចាប់កុមារចំនួន ១៣ នាក់ និងមនុស្សធំចំនួន ២៣ នាក់ ហើយបញ្ជូនពួកគេទៅអោយអង្គការក្តីញញឹមនៃកុមារ (PSE) ដែលអាជ្ញាធរបានអះអាងថា បានធ្វើការសហការជាមួយ នៅក្នុងប្រតិបត្តិការនោះ។ នៅពេលដឹងថា អ្នកទាំងនោះត្រូវបានប្រមូលពីតាមផ្លូវទាំងបង្ខំ អង្គការ PSE បានប្រគល់កុមារអោយឪពុកម្តាយគេវិញ ហើយអនុញ្ញាតអោយមនុស្សធំចាកចេញ។

<u>ការឃុំខ្លួនមុនសវនាការ៖</u> ច្បាប់អនុញ្ញាតអោយមានការឃុំខ្លួនមុនសវនាការរហូតដល់រយៈពេល ៦ ខែ ចំពោះបទល្មើសមជ្ឈិម និង ១៨ ខែ ចំពោះបទឧក្រិដ្ឋ។ គិតមកត្រឹមខែមិថុនា ក្រសួងមហាផ្ទៃបាននិយាយថា មានមនុស្សចំនួន ៣៥៦៦ នាក់ត្រូវបានឃុំខ្លួនមុនសវនាការ។ បុគ្គលិកតុលាការត្រូវបានរាយការណ៍មកថា បានខិតខំពន្លឿនការពិនិត្យសំរេចលើករណី ។ ថ្វីបើអ្នកជាប់ឃុំមុនសវនាការត្រូវបានឃុំដោយគ្មានតំណាង ជាមេធាវីក្តី តែគ្មានការរាយការណ៍មកថា មានការឃុំខ្លួនលើសពីរយៈពេលកំណត់ដោយច្បាប់ ឬក៏មានការបាត់បង់សំណុំរឿងទេ។

<u>ការលើកលែងទោស៖</u> ព្រះមហាក្សត្រអាចប្រទានការលើកលែងទោសក្នុងករណីខ្លះ ដែលជារឿយៗ ព្រះអង្គធ្វើឡើងនៅអំឡុងពិធីបុណ្យព្រះពុទ្ធសាសនាសំខាន់ៗ និងថ្ងៃបុណ្យជាតិ ។ នៅខែមេសា និងខែឧសភា ព្រះមហាក្សត្របានប្រទានការលើកលែងទោសដល់អ្នកជាប់ឃុំចំនួន ៨៩២ នាក់ នៅថ្ងៃបុណ្យចូលឆ្នាំខ្មែរ និងបុណ្យវិសាខបូជា។

## ខ. ការបដិសេធមិនអោយទទួលបានការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌

រដ្ឋធម្មនុញ្ញបានចែងថាតុលាការមានភាពឯករាជ្យ ប៉ុន្តែរដ្ឋាភិបាល ជាទូទៅ មិនគោរពឯករាជ្យភាពរបស់តុលាការឡើយ ។ តុលាការស្ថិតក្រោមឥទ្ធិពល និងការជ្រៀតជ្រែករបស់ផ្នែកនីតិប្រតិបត្តិ ហើយកើតមានអំពើពុករលួយយ៉ាងរាលដាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។ ជាញឹកញាប់លទ្ធផលនៃសវនាការហាក់មានការកំណត់ទុកជាមុនស្រេច។

កង្វះធនធាន ប្រាក់ខែទាប និងការបណ្តុះបណ្តាលមិនបានល្អនាំអោយមានកំរិតនៃអំពើពុករលួយខ្ពស់ និងអសមត្ថភាពក្នុងផ្នែកតុលាការ ហើយរដ្ឋាភិបាលមិនបានធ្វើអោយមានដំណើរការច្បាប់ត្រឹមត្រូវទេ។

អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា ករណីជាច្រើនមិនទាន់បានចាត់ការ ដោយសារខ្វះចៅក្រម និងបន្ទប់សវនាការ។ អង្គការមិនមែនរដ្ឋាភិបាលក៏បានធ្វើការកាត់ស្មានថា មន្ត្រីតុលាការប្រហែលផ្តោតការយកចិត្តទុកដាក់ច្រើនទៅលើករណីដែលគេអាចទទួលបានលុយ។

ការពន្យារពេលរបស់តុលាការ ឬអំពើពុករលួយរបស់តុលាការច្រើនតែធ្វើអោយជនរងការចោទប្រកាន់គេចផុតពីការកាត់ទោស។ មន្ត្រីរដ្ឋាភិបាល និងសមាជិកគ្រួសាររបស់គេដែលប្រព្រឹត្តបទល្មើស ច្រើនតែមិនបានទទួលទោសឡើយ (និទណ្ឌភាព)។ អង្គការមិនមែនរដ្ឋាភិបាលបានអះអាងថា ក្នុងករណីព្រហ្មទណ្ឌជាច្រើន ចុងចោទដែលមានទ្រព្យឬមានអំណាច រួមទាំងសមាជិកនៃកងកំលាំងសន្តិសុខផង តាមធម្មតា

បង់លុយអោយជនរងគ្រោះ និងអាជ្ញាធរ ដើម្បីអោយទំលាក់ការចោទប្រកាន់ព្រហ្មទណ្ឌ។ អាជ្ញាធរត្រូវបានគេដឹងថា បានតឿនអោយជនរងគ្រោះ ឬគ្រួសាររបស់គេទទួលយកសំណងប៉ះប៉ូវជាលុយកាក់ ជាថ្នូរនឹងការទំលាក់ចោលការចោទប្រកាន់ព្រហ្មទណ្ឌ ឬការមិនបង្ហាញមុខជាសាក្សី។

## នីតិវិធីជំនុំជម្រះក្តី

សវនាការត្រូវបានធ្វើជាសាធារណៈ។ ចុងចោទមានសិទ្ធិ បង្ហាញវត្តមាន ហើយពិគ្រោះយោបល់ជាមួយមេធាវី ប្រឈម និងចោទសួរសាក្សីប្រឆាំងនឹងខ្លួន ហើយ បង្ហាញសាក្សី និងភស្តុតាងដោយខ្លួនគេ។ ក្នុងករណីព្រហ្មទណ្ឌ ប្រសិនបើចុងចោទគ្មានប្រាក់រកមេធាវីម្នាក់បាន តុលាការត្រូវផ្តល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ចុងចោទ ។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ តុលាការតែងតែខ្វះធនធានដើម្បីផ្តល់ប្រឹក្សាផ្នែកច្បាប់ ហើយចុងចោទភាគច្រើនស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬត្រូវឡើងតុលាការដោយគ្មានតំណាងផ្នែកច្បាប់ ។ ការជំនុំជម្រះក្តីច្រើនតែធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ច ហើយការសួរដេញដោលច្រើនពីភាគីម្ខាងទៅភាគីម្ខាង ជាធម្មតា មិនមានឡើយ ។ ចុងចោទ និងមេធាវីរបស់ខ្លួនមានសិទ្ធិពិនិត្យមើលភស្តុតាងដែលរដ្ឋាភិបាលរក្សាទុក ទាក់ទងនឹងរឿងក្តីរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ គេច្រើនមានការពិបាកនឹងទទួលបានលទ្ធភាពដូចពោលនេះណាស់ ជាពិសេស ប្រសិនបើសំណុំរឿងនោះពាក់ព័ន្ធនឹងរឿងនយោបាយ ឬពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ឬបុគ្គលដែលមានខ្សែរយៈរឹងមាំ ។

មានការខ្វះមេធាវីច្រើនដែលមានជំនាញត្រឹមត្រូវ ពិសេសនៅក្រៅក្រុងភ្នំពេញ។ អ្នកដែលគ្មានធនធានសំរាប់រកមេធាវី បាត់បង់សិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌។ យោងតាមសមាគមនៃគណមេធាវីដោយគិតមកត្រឹមខែសីហា មានមេធាវីចំនួន ៧២៥ នាក់ផ្តល់សេវាផ្លូវច្បាប់នៅទូទាំងប្រទេស។ អ្នកក្រអាចស្វែងរកសេវាផ្លូវច្បាប់ដោយឥតគិតថ្លៃពីមេធាវីទាំងនេះ តាមរយៈអង្គការមិនមែនរដ្ឋាភិបាលខ្លះ។

តាមច្បាប់ ចុងចោទមានសិទ្ធិត្រូវបានគេសន្មតថា ជាជនស្លូតត្រង់ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ ប៉ុន្តែដោយសារអំពើពុករលួយរីករាលដាល ជារឿយៗចុងចោទត្រូវបានគេរំពឹងអោយសូកថៅក្រម ដើម្បីអោយចេញសាលក្រមដែលមានលក្ខណៈអនុគ្រោះ ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា មានតែការថ្លែងជាលាយលក្ខណ៍អក្សររបស់សក្សី និងអ្នករងការចោទប្រកាន់ទេដែលជាធម្មតា ត្រូវបានយកធ្វើជាភស្តុតាងនៅក្នុងសវនាការ។ ពេលខ្លះ ជនរងការចោទប្រកាន់ត្រូវបានបង្ខំអោយនិយាយ ដោយការវាយដំ ឬការគំរាមកំហែង ហើយចុងចោទដែលមិនចេះអក្សរ ជាញឹកញាប់ មិនត្រូវបានប្រាប់ពីសេចក្តីនៅក្នុងចំលើយសារភាពដែលគេត្រូវបានបង្ខំអោយចុះហត្ថលេខាទៅលើនោះទេ។ សិទ្ធិរបស់ពលរដ្ឋក្នុងការមានវត្តមាន

នៅក្នុងសាលាឧទ្ធរណ៍ ជាញឹកញាប់មានកំរិត ដោយសារការពិបាកនៅក្នុងការផ្ទេរអ្នកទោសពីពន្ធនាគារខេត្ត មកសាលាឧទ្ធរណ៍នៅភ្នំពេញ។ ដូច្នេះ ជាងពាក់កណ្ដាលនៃសវនាការឧទ្ធរណ៍ប្រព្រឹត្តទៅដោយគ្មានវត្តមាន របស់ចុងចោទឡើយ។

## អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយ

នៅថ្ងៃទី ១៥ ខែកក្កដា នគរបាលបានចាប់ខ្លួនសមាជិកសភាជាប់ឆ្នោត ៤ រូប មកពីគណបក្សសង្គ្រោះជាតិកម្ពុជា ដែលជាគណបក្សប្រឆាំង នៅក្នុងអំឡុងពេលនៃការតវ៉ា ដែលទាមទារអោយអាជ្ញាធរលុបចោលបំរាមសួនប្រជាធិបតេយ្យ។ ការចាប់ខ្លួនត្រូវបានធ្វើឡើងបន្ទាប់ពីអ្នកតវ៉ាបានប៉ះទង្គិចជាមួយកំលាំងសន្តិសុខខ័ណ្ឌដូនពេញ ដែលបានធ្វើអោយកំលាំងសន្តិសុខចំនួន ៩ នាក់រងរបួស។ នៅថ្ងៃបន្ទាប់ នគរបាលបានចាប់ខ្លួនសមាជិកសភាជាប់ឆ្នោតនៃគណបក្សប្រឆាំងម្នាក់ទៀត និងយុវជនជាសកម្មជនម្នាក់ ហើយនៅថ្ងៃទី ១៧ ខែកក្កដា នគរបាលបានចាប់ខ្លួនសមាជិកសភាជាប់ឆ្នោតនៃគណបក្សប្រឆាំងម្នាក់ទៀត។ អាជ្ញាធរបានឃុំខ្លួនសមាជិកសភាជាប់ឆ្នោតនៃគណបក្សប្រឆាំងចំនួន ៧ រូប និងយុវជនជាសកម្មជនមួយរូប នៅពន្ធនាគារព្រៃស ដោយរង់ចាំសវនាការ។ នៅថ្ងៃទី ២២ ខែកក្កដា តុលាការក្រុងភ្នំពេញបានដោះលែងអោយសមាជិកសភាជាប់ឆ្នោតនៃគណបក្សប្រឆាំង និងយុវជនជាសកម្មជនអោយនៅក្រៅឃុំ បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំង បានព្រមព្រៀងគ្នាបញ្ចប់ការជាប់គាំងនយោបាយ ដែលកើតចេញពីជំលោះលើការបោះឆ្នោតជាតិឆ្នាំ ២០១៣។ នៅថ្ងៃទី ១១ និងថ្ងៃទី ១២ ខែវិច្ឆិកា នគរបាលបានចាប់ខ្លួនមន្ត្រីនៃគណបក្សប្រឆាំង CNRP ពីររូប ដោយចោទពីបទបះបោ កើតចេញពីការប៉ះទង្គិចគ្នា កាលពីថ្ងៃទី ១៥ ខែកក្កដា។ អ្នកសង្កេតការណ៍ជាច្រើនបានបកស្រាយសកម្មភាពទាំងនេះថា ជាមធ្យោបាយមួយដើម្បីគាបសង្កត់គណបក្សប្រឆាំង នៅក្នុងការចរចាដែលមានការជាប់គាំង ដើម្បីធ្វើការកែទំរង់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## នីតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ

ប្រទេសកម្ពុជាមានអង្គតុលាការមួយសម្រាប់បណ្ដឹងរដ្ឋប្បវេណី ហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្ដឹងស្វែងរកសំណងការខូចខាតចំពោះការរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងដំណោះស្រាយផ្នែករដ្ឋបាល ទាំងដំណោះស្រាយផ្នែកតុលាការ ។ ជាញឹកញាប់ អាជ្ញាធរមិនអនុវត្តសាលដីកាតុលាការទេ។

## ច. ការជ្រៀតជ្រែកក្នុងភាពឯកជន គ្រួសារ គេហដ្ឋាន ឬការឆ្លើយឆ្លងគ្នា

ច្បាប់មានចែងអំពីភាពឯកជននៃលំនៅដ្ឋាន និងការឆ្លើយឆ្លងគ្នា ហើយហាមឃាត់ការឆែកឆេរខុសច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយក៏អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថាជាទម្លាប់ នគរបាលធ្វើការឆែកឆេរ និងរឹបអូស ដោយគ្មានដីកាពីតុលា ។

ការប្រមូលជាសម្ហាភាពដោយបង្ខំនៅអំឡុងសម័យខ្មែរក្រហម និងការបំលាស់ទីរបស់ប្រជាជនជាច្រើនបានធ្វើអោយកម្មសិទ្ធិដីធ្លីមានលក្ខណៈមិនច្បាស់លាស់ ។ ច្បាប់ភូមិបាលចែងថា បុគ្គលណាដែលបានកាន់កាប់ដី និងអាគាររដ្ឋ (មិនមែនដីសាធារណៈ ដូចជាសួនឧទ្យាន) ដោយគ្មានការជំទាស់ រយៈពេល៥ឆ្នាំមុនពេលប្រកាសអោយប្រើច្បាប់ភូមិបាលឆ្នាំ២០០១ មានសិទ្ធិសុំកម្មសិទ្ធិផ្តាច់មុខលើដីឬអាគារនោះ ។ ប្រជាជនភាគច្រើនក្នុងប្រទេសនៅតែខ្វះការយល់ដឹង និងមធ្យោបាយដើម្បីទទួលបានឯកសារផ្លូវការគ្រប់គ្រាន់ទាក់ទងនឹងកម្មសិទ្ធិដីធ្លី ។

ការិយាល័យសុរិយោដីខេត្តនិងស្រុកនៅតែបន្តអនុវត្តតាមនីតិវិធីចុះបញ្ជីដីធ្លីមុនឆ្នាំ២០០១ ដែលពុំមានការវាស់វែងដីត្រឹមត្រូវ និងឱកាសសម្រាប់ការផ្តល់យោបល់ពីសាធារណជនទេ ។ គណៈកម្មការសុរិយោដីមិនបានអនុវត្តការកំណត់អត្តសញ្ញាណ និងកំណត់ព្រំដីរបស់រដ្ឋ ដែលជាការនាំអោយមានទំនាស់ដីធ្លី និងការបណ្តេញ ដែលមានរឹតតែលឿនដោយសារការអភិវឌ្ឍរបស់រដ្ឋលើដីមានទំនាស់ ។ ការទិញលក់ដីយកចំណេញជំរុញអោយមានទំនាស់នៅគ្រប់ខេត្ត ហើយភាពតានតឹងមានកាន់តែខ្លាំងរវាងសហគមន៍ក្រីក្រនៅតាមជនបទ និងឈ្មួញដី ។ សហគមន៍តាមទីក្រុង ប្រឈមមុខនឹងការបណ្តេញចេញដោយបង្ខំ ដើម្បីបើកផ្លូវអោយគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន។ នៅឆ្នាំ ២០១២ រដ្ឋាភិបាលបានផ្តើមកម្មវិធីមួយដែលប្រើនិស្សិតសាកលវិទ្យាល័យចំនួនប្រហែល ១000 នាក់ អោយចុះវាស់វែងក្បាលដី ដោយសហការជាមួយក្រសួងគ្រប់គ្រងដែនដី។  ដោយគិតត្រឹមខែឧសភា ក្រសួងរៀបចំដែនដីបានរាយការណ៍ថា ប័ណ្ណកម្មសិទ្ធិដីចំនួនជិត ៥00 000 ត្រូវបានចែកដល់អ្នកភូមិ ជាផ្នែកមួយនៃគំរោងនេះ។

ករណីអ្នកស្រុកត្រូវបានបណ្តេញអោយផ្លាស់ប្តូរទីលំនៅនៅតែបន្តកើតមាន តែចំនួនករណីដែលត្រូវបានរាយការណ៍មកមានការថយចុះពីឆ្នាំ ២០១៣។ មានបុគ្គលមួយចំនួនបានប្រើប្រាស់ការគំរាមប្តឹង ឬការបណ្តេញចេញ ដើម្បីបំភិតបំភ័យប្រជាជនក្រីក្រ និងជនងាយរងគ្រោះអោយដោះដូរដីធ្លីរបស់ខ្លួន យកសំណងដែលទាបជាងតម្លៃទីផ្សារ ។ អង្គការ ADHOC បានរាយការណ៍ថា ខ្លួនបានទទួលករណីទាក់ទងនឹងដីធ្លីចំនួន ៧៥ ករណី ដោយគិតត្រឹមខែមិថុនា ។ នៅអំឡុងពេលនេះដែរ អង្គការមិនមែនរដ្ឋាភិបាលមួយផ្សេងទៀតបានទទួលបណ្តឹងទាក់ទងនឹងបញ្ហាដីធ្លីចំនួន ៥១ ករណីនៅភ្នំពេញ និងខេត្តចំនួន ១២ ដែលប៉ះ ពាល់ដល់ប្រជាជនចំនួន ៤៤៩៥ គ្រួសារ ។ ជារឿយៗ ប្រជាជនក្រីក្រគ្មានឯកសារផ្លូវច្បាប់ដើម្បីបញ្ជាក់លើការទាមទារដីធ្លី

របស់ខ្លួនឡើយ ហើយខ្វះជំនឿទៅលើប្រព័ន្ធតុលាការ ។ ប្រជាជនមួយចំនួនដែលត្រូវបានបណ្តេញចេញបានតវ៉ាដោយជោគជ័យប្រឆាំងនឹងវិធានការទាំងនេះនៅក្នុងតុលាការ ប៉ុន្តែករណីភាគច្រើននៅក្នុងតុលាការកំពុងស្ថិតក្នុងដំណើរការពិនិត្យសំណុំឯកសារនៅឡើយ ។

## ផ្នែកទី២ ៖ ការគោរពសេរីភាពពលរដ្ឋ ដែលរួមមាន

### ក. សេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន

រដ្ឋធម្មនុញ្ញមានចែងពីសេរីភាពបញ្ចេញមតិ និងសេរីភាពផ្នែកសារព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង សិទ្ធិទាំងនេះមិនត្រូវបានគោរពជានិច្ចឡើយ ។

សេរីភាពក្នុងការបញ្ចេញមតិ៖រដ្ឋធម្មនុញ្ញកំណត់ថា ការបញ្ចេញមតិដោយសេរី មិនត្រូវប៉ះពាល់ដល់សន្តិសុខសាធារណៈឡើយ ។ រដ្ឋធម្មនុញ្ញ ក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ “មិនអាចត្រូវគេរំលោភបានទេ” ហើយសេចក្តីណែនាំរបស់ ក្រសួងមហាផ្ទៃ ដែលអនុលោមតាមច្បាប់បរិហាកេរ្តិ៍ បញ្ជាក់ជាថ្មីនូវដែនកំណត់ទាំងនេះ ហើយហាមប្រាម មិនអោយអ្នកបោះពុម្ព និងនិពន្ធនាយកផ្សព្វផ្សាយរឿងណា ដែលប្រមាថនិងបរិហាកេរ្តិ៍ថ្នាក់ដឹកនាំ និងស្ថាប័ន រដ្ឋាភិបាលឡើយ ។

ច្បាប់ហាមប្រាមមិនអោយមានការត្រួតពិនិត្យចាប់ពិរុទ្ធមុនពេលបោះពុម្ពផ្សាយ ឬការដាក់ទោសជាប់ពន្ធនាគារ ដោយសារការសម្តែងមតិឡើយ ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានប្រើក្រមព្រហ្មទណ្ឌដើម្បីកាត់ទោសពីបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់។ ក្រមព្រហ្មទណ្ឌមិនមានចែងពីការចាប់ដាក់ពន្ធនាគារចំពោះការបរិហារកេរ្តិ៍ទេ តែចែងពីការដាក់ពន្ធនាគារចំពោះការញុះញង់ ឬផ្សាយព័ត៌មានមិនពិត ដែលអាចនាំអោយមានការចាប់ដាក់ពន្ធនាគាររហូតដល់ ៣ ឆ្នាំ។ ចៅក្រមក៏អាចបញ្ជាអោយបង់ការផាកពិន័យផងដែរ ដែលអាចនាំអោយមានការចាប់ដាក់ពន្ធនាគារ បើមិនបង់ទេ។

<u>សេរីភាពសារព័ត៌មាន៖</u>គណបក្សនយោបាយធំៗទាំងអស់មានលទ្ធភាពប្រើប្រាស់កាសែតបានយ៉ាងសមហេតុផល និងទៀងទាត់។ កាសែតធំៗទាំងអស់ជាភាសាខ្មែរទទួលបានការគាំទ្រថវិកាពីបុគ្គលដែលស្និទ្ធនឹងគណបក្សនយោបាយ ហើយចូលជាសមាជិកគណបក្ស។ មានកាសែតជាភាសាខ្មែរប្រមាណ ២០ ត្រូវបានបោះពុម្ពជាប្រចាំ។ គិតមកត្រឹមខែសីហា មានកាសែតប្រឆាំង ២ ត្រូវបានបោះពុម្ពជាប្រចាំ ។ ថ្វីបើកាសែតចំនួន

៥ ដែលបោះពុម្ពច្រើនជាងគេ ត្រូវបានចាត់ទុកថា គាំទ្រគណបក្សប្រជាជនក្តី តែកាសែតភាគច្រើនរិះគន់រដ្ឋាភិបាលដោយនិយាយមិនចំ ពិសេសទាក់ទងនឹងអំពើពុករលួយ និងការចាប់យកដី។

រដ្ឋាភិបាល កងកំលាំងយោធា និងគណបក្សនយោបាយកាន់អំណាចបានបន្តគ្រប់ដណ្តប់លើប្រព័ន្ធផ្សព្វផ្សាយ ហើយមានឥទ្ធិពលលើខ្លឹមសារនៃការផ្សាយ។ មានស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកចំនួន ១២ ហើយ និងស្ថានីយ៍វិទ្យុចំនួនជិត ១០០។ ស្ថានីយ៍វិទ្យុភាគច្រើន និងស្ថានីយ៍ទូរទស្សន៍ទាំងអស់ត្រូវបានគ្រប់គ្រង ឬស្ថិតក្រោមឥទ្ធិពលយ៉ាងខ្លាំងរបស់គណបក្សប្រជាជនកម្ពុជា ហើយមានតែចំនួនតិចតួចទេដែលឯករាជ្យ ឬមិនកាន់ខាងគណបក្សឯទៀ។

<u>អំពើហឹង្សា និងការយាយី៖</u> ពេលខ្លះ កំលាំងសន្តិសុខរបស់រដ្ឋាភិបាលវាយប្រហារមកលើអ្នកសារព័ត៌មាន។ នៅថ្ងៃទី ២ ខែឧសភា អ្នកយាមការពារសន្តិសុខខ័ណ្ឌដូនពេញបានដេញវាយអ្នកសារព័ត៌មានរបស់វិទ្យុសំលេងប្រជាធិបតេយ្យ (VOD) ឈ្មោះឡាយ សាមៀន ក្នុងពេលដែលលោកយកព័ត៌មានស្តីពីយុទ្ធនាការបោះឆ្នោតក្រុមប្រឹក្សា នៅសួនប្រជាធិបតេយ្យ ក្នុងរាជធានីភ្នំពេញ ដែលជាកន្លែងត្រូវបានកំណត់ទុកសំរាប់ការធ្វើបាតុកម្ម និងពិធីធំៗដទៃទៀត។ លោកសាមៀនបានរងរបួសយ៉ាងធ្ងន់នៅលើមុខ ដែលតំរូវអោយគាត់ទៅព្យាបាលនៅប្រទេសថៃ។ វិទ្យុ VOD បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងអភិបាលរងខ័ណ្ឌ ហើយគិតមកដល់ខែសីហា តុលាការក្រុងភ្នំពេញមិនទាន់ចាត់វិធានការលើពាក្យបណ្តឹងនេះនៅឡើយទេ។

<u>ការចាប់ពិរុទ្ធ ឬការដាក់កំហិតលើសេចក្តីក្នុងអត្ថបទ៖</u> មានរបាយការណ៍ខ្លះថា ភ្នាក់ងាររបស់រដ្ឋាភិបាលបានយាយី ឬគំរាមអ្នកសារព័ត៌មាន អ្នកបោះពុម្ពផ្សាយ ឬអ្នកចែកចាយ ហើយអ្នកសារព័ត៌មាន និងចាងហ្វាងសារព័ត៌មានលួចសារភាពថាមិនបានសរសេរអោយអស់ទេ ពីព្រោះខ្លាចរដ្ឋាភិបាលសងសឹក។

**សេរីភាពអ៊ីនធ័រណែត**

គ្មានរបាយការណ៍និយាយអំពីការដាក់កំហិតរបស់រដ្ឋាភិបាលលើប្រព័ន្ធអ៊ិនធ័រណែត ឬមានរបាយការណ៍គួរអោយទុកចិត្តបានថារដ្ឋាភិបាលបានតាមដានអ៊ីម៉ែល ឬការឆ្លើយឆ្លងផ្ទាល់តាមអ៊ីនធ័រណែត ដោយគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ទេ ។ ជាទូទៅ គេមានអ៊ិនធ័រណែតប្រើប្រាស់ ពិសេសនៅតាមតំបន់ទីប្រជុំជន ហើយប្រហែល ២៨% នៃប្រជាជនកម្ពុជាអាចប្រើសេវាអ៊ិនធ័រណែតតាមរយៈទូរស័ព្ទដៃរបស់គេ។ នេះបើតាមព័ត៌មានពីក្រសួងទូរគមនាគមន៍ និងប្រៃសនីយ៍។

## សេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌

ជាទូទៅ ពុំមានឧបសគ្គចំពោះសេរីភាពផ្នែកការសិក្សាអប់រំឬពិធីវប្បធម៌ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារខ្លាចប៉ះពាល់អ្នកនយោបាយ ។

## ខ. សេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី និងសេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋធម្មនុញ្ញមានចែងពីសេរីភាពប្រមូលផ្តុំគ្នាដោយសន្តិវិធី ប៉ុន្តែមានពេលខ្លះ រដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះទេ នៅក្នុងការអនុវត្តជាក់ស្តែង ។

ច្បាប់តំរូវអោយមានការសុំការអនុញ្ញាតជាមុន មុននឹងធ្វើការដង្ហែរក្បួនតវ៉ា ឬបាតុកម្ម។ បញ្ញាតិមួយចែងពីការជំរាបប្រាប់ចំនួន ៥ ថ្ងៃមុន សំរាប់ការធ្វើបាតុកម្មដោយសន្តិវិធី ចំណែកបញ្ញាតិមួយទៀតចែងពីការតំរូវអោយជូនដំណឹងចំនួន ១២ ម៉ោងមុន សំរាប់ការប្រមូលផ្តុំគ្នាដោយមិនមានការគ្រោងទុក នៅលើទីកន្លែងឯកជន ឬនៅទីកន្លែងតវ៉ាដោយសន្តិវិធី ក្នុងខេត្តនិមួយៗ ហើយកំរិតចំនួនអ្នកចូលរួមត្រឹម ២០០ នាក់។ តាមច្បាប់ អាជ្ញាធរខេត្ត និងអាជ្ញាធរក្រុងមានអំណាចសំរេចចេញការអនុញ្ញាតអោយធ្វើបាតុកម្ម។ តាមភាពជាក់ស្តែង ពិសេសនៅភ្នំពេញ មន្ត្រីអាជ្ញាធរថ្នាក់ក្រោមប្រគល់សិទ្ធិអោយអាជ្ញាធរថ្នាក់ជាតិវិញ ក្នុងការសំរេច ហើយធ្វើការបដិសេធសំណើសុំ បើអាជ្ញាធរថ្នាក់ជាតិមិនផ្តល់ការអនុញ្ញាតច្បាប់អោយធ្វើការប្រមូលផ្តុំគ្នាទេ។ តាមធម្មតា អាជ្ញាធរមិនផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់គណបក្សដឹកនាំប្រទេស ។អាជ្ញាធរលើកហេតុផលស្ថេរភាព និងសន្តិសុខសាធារណៈសំរាប់ការមិនផ្តល់ការអនុញ្ញាត។ តែច្បាប់មិនកំណត់ច្បាស់នូវន័យនៃពាក្យថាស្ថេរភាព និងសន្តិសុខសាធារណៈសំរាប់ធ្វើជាហេតុផលក្នុងការបដិសេធការអនុញ្ញាតទេ ។ ក្នុងករណីខ្លះ នគរបាលបំបែកហ្វូងមនុស្សដែលប្រមូលផ្តុំគ្នាដោយគ្មានការអនុញ្ញាតិ ដោយក្នុងករណីខ្លះបណ្តាលអោយមានរបួសតិចតួចដល់បាតុករខ្លះ។ ផ្នែកសារព័ត៌មានបានរាយការណ៍ថា មានតវ៉ាជាសាធារណៈច្រើន ដោយភាគច្រើនទាក់ទងនឹងរឿងដីធ្លី ឬជំលោះការងារ។

ជាការឆ្លើយតបនឹងកំណើននៃអំពើហឹង្សាដែលកើតចេញពីការតវ៉ារបស់កម្មករ រដ្ឋាភិបាលបានហាមប្រាមការប្រមូលផ្តុំនយោបាយទាំងអស់ នៅភ្នំពេញ កាលពីថ្ងៃទី ៤ ខែមករា។ ការអនុវត្តរបស់រដ្ឋាភិបាលមិនស៊ីចង្វាក់គ្នាទេ។ ពេលខ្លះ បាតុកម្មតូចៗទាក់ទងនឹងសិទ្ធិដីធ្លីត្រូវបានអនុញ្ញាត ហើយការប្រមូលផ្តុំគ្នាដ៏ធំមួយដែលគាំទ្ររដ្ឋាភិបាលបានប្រព្រឹត្តទៅដោយគ្មានការរំខាន។ សួនប្រជាធិបតេយ្យត្រូវបានហ៊ុំរបងជិត ពីថ្ងៃទី ៤

មករា ដល់ថ្ងៃទី ៦ សីហា ដែលជាថ្ងៃដែលគណបក្សប្រឆាំងវិលត្រឡប់ចូលសភាជាតិវិញ។ នៅក្នុងអំឡុងពេលនេះ អាជ្ញាធរបានបំបែកការប្រមូលផ្តុះតូចៗដោយសន្តិភាពមួយចំនួន ដោយពេលខ្លះ បាននាំអោយមានការប៉ះទង្គិចគ្នា របួស និងការចាប់ខ្លួន។

ពិតមែនតែបំរាមលើការប្រមូលផ្តុំគ្នាមានតែនៅភ្នំពេញក្តី តែនៅថ្ងៃទី ២១ ខែមករា មេដឹកនាំគណបក្សសង្គ្រោះជាតិបានលុបចោលផែនការជួបជុំជាមួយអ្នកគាំទ្រគណបក្ស នៅស្រុកស្អាង ខេត្តកណ្តាល ក្រោយពីលឺថា មានអ្នកគាំទ្រគណបក្សប្រជាជនរាប់រយនាក់ធ្វើការតវ៉ាប្រឆាំងតប នៅកន្លែងរៀបចំនោះ។ យោធា និងនគរបាលខេត្តនៅនឹងកន្លែងត្រូវបានរាយការណ៍មកថា មិនសូវរវីរវល់ក្នុងការធានាសន្តិសុខសំរាប់អ្នកគាំទ្រគណបក្សប្រឆាំងឡើយ។

**សេរីភាពបង្កើតអង្គការ/សមាគម**

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគម តែរដ្ឋាភិបាលមិនបានគោរពសិទ្ធិ នេះអោយបានជាប់លាប់ទេ នៅក្នុងការអនុវត្តជាក់ស្តែង ពិសេសទាក់ទងនឹងសិទ្ធិរបស់កម្មករ (សូមមើលត្រង់ផ្នែក ៧.ក) ។

**គ. សេរីភាពសាសនា**

សូមមើល *របាយការណ៍ស្តីពីសេរីភាពសាសនា* តាមគេហទំព័រ
www.state.gov/religiousfreedomreport

**ឃ. សេរីភាពដើរហើរ ជនផ្លាស់ទីកន្លែងក្នុងប្រទេស ការការពារជនភៀសខ្លួន និងជនគ្មានប្រទេស**

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរនៅបរទេស និរប្រវេសន៍ និងមាតុភូមិនិវត្តន៍ ហើយជាទូទៅ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ ។ រដ្ឋាភិបាលបានធ្វើសហប្រតិបត្តិការជាមួយការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) និងអង្គការមនុស្សធម៌ដទៃទៀតក្នុងការផ្តល់កិច្ចការពារ ឬជំនួយដល់ជនផ្លាស់ទីលំនៅក្នុងស្រុក ជនភៀសខ្លួនមាតុភូមិនិវត្តន៍ អ្នកស្វែងរកសិទ្ធិជ្រកកោន ជនគ្មានប្រទេស ឬបុគ្គលដែលធ្វើអោយមានក្តីបារម្ភ ដទៃទៀត។

<u>ការធ្វើនិរប្រវេសន៍ និងការធ្វើមាតុភូមិនិវត្តន៍៖</u> កម្មករចំណាកស្រុកកម្ពុជាយ៉ាងតិច ២៥០ ០០០ នាក់ ដោយរួមទាំងកុមារចំនួនជាង ១៥ ០០០ នាក់ផង ត្រូវបានធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត ពីប្រទេសថៃ បន្ទាប់ពីរដ្ឋាភិបាលថៃបានប្រកាសថា នឹងចាប់បញ្ជូនមកវិញនូវកម្មករចំណាកស្រុកខុសច្បាប់ដែលកំពុងរស់នៅក្នុងប្រទេសថៃ។ ក្នុងពេលគេវិលត្រឡប់មកវិញ  អាជ្ញាធរកម្ពុជាបានធ្វើការជិតស្និទ្ធជាមួយសង្គមស៊ីវិល និងអង្គការអន្តោប្រវេសន៍អន្តរជាតិ (IOM) ដើម្បីផ្តល់ជំរក ស្បៀង ទឹក ការថែទាំសុខភាព និងការដឹកជញ្ជូនដោយមិនគិតថ្លៃ ពីព្រំដែនមកភូមិកំណើតរបស់គេ នៅពេលពួកគេមកដល់ព្រំដែន។

## ការការពារជនភៀសខ្លួន

<u>លទ្ធភាពទទួលបានការជ្រកកោន៖</u> ច្បាប់ប្រទេសកម្ពុជាមានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាលបានរៀបចំប្រព័ន្ធមួយសម្រាប់ផ្តល់កិច្ចការពារដល់ជនភៀសខ្លួន ។ ប្រព័ន្ធជាតិស្តីពីសិទ្ធិជ្រកកោនមាន សមត្ថភាពនៅមានកំរិត ដែលជាការនាំអោយមានការពន្យារពេលវែង សំរាប់អ្នកសុំសិទ្ធិជ្រកកោនខ្លះ។

អង្គការ UNHCR បានបន្តផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដទៃទៀតដល់ការិយាល័យជនភៀសខ្លួនខ្មែរ នៅក្នុងនាយកដ្ឋានអន្តោប្រវេសន៍។ ការការពារត្រូវបានផ្តល់ស្របតាមអនុសញ្ញាឆ្នាំ ១៩៥១ ស្តីពីជនភៀសខ្លួន ហើយនិងពិធីសារ ឆ្នាំ ១៩៦៧ តែគេនៅតែមានកង្វល់ស្តីពីសមត្ថភាពរបស់ប្រព័ន្ធនេះ នៅក្នុងការដោះស្រាយចំពោះជនភៀសខ្លួនដែលមានចំនួនច្រើន។

## ជនគ្មានប្រទេស [ជនគ្មានរដ្ឋ]

ប្រទេសកម្ពុជាមានអ្នករស់នៅដែលជាជនគ្មានប្រទេស ចំណែកឯរដ្ឋាភិបាលមិនបានអនុវត្តច្បាប់ឬគោលនយោបាយប្រកបដោយប្រសិទ្ធភាពដើម្បីផ្តល់ឱកាសដល់ជនទាំងនោះអោយទទួលបានសញ្ជាតិឡើយ ។ តាមច្បាប់សញ្ជាតិ ឋានៈជាពលរដ្ឋអាចទទួលបានពីកំណើតដោយសារម្តាយ និងឪពុកដែលមិនមែនជាតិខ្មែរ ប្រសិនបើអ្នកទាំងពីរបានកើត និងកំពុងរស់នៅដោយស្របច្បាប់នៅប្រទេសកម្ពុជា ឬប្រសិនបើឪពុក ឬម្តាយបានទទួលឋានៈជាពលរដ្ឋកម្ពុជា ។

ការសិក្សាមួយនៅឆ្នាំ២០០៧ ដោយអង្គការ UNHCR ប៉ាន់ប្រមាណថា អ្នកដែលប្រហែលជាគ្មានប្រទេស ជាច្រើនពាន់នាក់បានរស់នៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ស្មានរបស់ការសិក្សានេះបានមកពីភស្តុតាងដែលគ្មានលក្ខណៈច្បាស់លាស់ ហើយតំណាងរបស់អង្គការ UNHCR នៅ

ក្នុងស្រុកមិនបានចាត់ទុកថាតួលេខទាំងនេះថាមានលក្ខណៈប្រាកដប្រជាឡើយ ។ ហេតុផលដែលច្រើនមានជាងគេចំពោះភាពគ្មានប្រទេសគឺកង្វះឯកសារត្រឹមត្រូវពីប្រទេសដើម។

អង្គការ UNHCR រាយការណ៍ថា ប្រជាជនដែលគ្មានប្រទេសនៅកម្ពុជា ភាគច្រើនគឺក្រុមអាណិកជនវៀតណាម។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងសញ្ជាតិ ច្រើនមិនទទួលបានការងារដែលមានលក្ខណៈផ្លូវការ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ លទ្ធភាពតាមផ្លូវតុលាការ និងកម្មសិទ្ធិដីធ្លីទេ។

## ផ្នែកទី៣. ការគោរពសិទ្ធិនយោបាយ ៖ សិទ្ធិពលរដ្ឋក្នុងការផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួន

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួនដោយសន្តិវិធី ហើយជាទូទៅប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិនេះនៅក្នុងការអនុវត្តជាក់ស្តែង តាមរយៈការបោះឆ្នោតតាមពេលវេលាទៀងទាត់ និងជាសាកល ។

## ការបោះឆ្នោត និងការចូលរួមផ្នែកនយោបាយ

<u>ការបោះឆ្នោតជាតិថ្មីៗកន្លងទៅ៖</u> ការបោះឆ្នោតជាតិក្នុងពេលថ្មីៗបំផុត ដែលត្រូវបានធ្វើនៅខែកក្កដា ជារួមមានលក្ខណៈស្ងប់ស្ងាត់ល្អ ហើយគ្រប់គណបក្សទាំងអស់បានចូលរួមក្នុងយុទ្ធនាការដោយគ្មានការរារាំង ហើយជាទូទៅ គ្មានការគំរាមកំហែង ដែលផ្ទុយពីការបោះឆ្នោតជាតិលើកមុនៗ។ ថ្វីត្បិតតែមានការរំជើបរំជួលមិនច្រើននៅថ្ងៃបោះឆ្នោតក្តី តែដំណើរការបោះឆ្នោតគឺពោរពេញដោយភាពមិនប្រក្រតី។ តាមការគណនារបស់រដ្ឋាភិបាលខ្លួនឯង អ្នកមានសិទ្ធិបោះឆ្នោតចំនួនជាង ៩% មិនអាចបោះឆ្នោតបានដោយសារបញ្ហាបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ថ្វីត្បិតតែបញ្ហានៃអ្នកបោះឆ្នោតមិនអាចទៅបោះឆ្នោតត្រូវបានរកឃើញដោយអង្គការសង្គមស៊ីវិលជាច្រើន នៅមុនពេលបោះឆ្នោតរយៈពេលយ៉ាងយូរក្តី តែគជបមិនបានធ្វើការកែតំរូវអ្វីគួរអោយកត់សំគាល់ទេ។ អ្នកសង្កេតការណ៍បានកត់សំគាល់ឃើញថា កំរិតនៃភាពមិនប្រក្រតីក្នុងការបោះឆ្នោតសមល្មមនឹងធ្វើការស៊ើបអង្កេតដោយឯករាជ្យមួយ តែការស៊ើបអង្កេតពេញលេញ និងដោយឯករាជ្យមិនត្រូវបានធ្វើទេ។ គណបក្ស CNRP មិនព្រមចូលរួមអង្គុយក្នុងសភាជាតិទេ រហូតដល់មានកិច្ចព្រមព្រៀងថ្ងៃទី ២២ កក្កដា រវាងគណបក្សទាំងពីរ លើការកែទំរង់ គជប។

គណបក្សនយោបាយ និងការចូលរួមនយោបាយ៖ អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយមួយចំនួនបានចោទប្រកាន់ថា សមាជិកភាពនៅក្នុងគណបក្សប្រជាជនកម្ពុជាដែលមានភាពគ្របដណ្តប់លើគេ បានផ្តល់អត្ថប្រយោជន៍ ដូចជាអំណោយ ជំនួយសង្គ្រោះបន្ទាន់របស់រដ្ឋាភិបាល និងសម្បទានដីសេដ្ឋកិច្ច ។ គណបក្សប្រជាជនកម្ពុជាមានលទ្ធភាពទទួលបានការផ្សព្វផ្សាយលើសលុបពីប្រព័ន្ធផ្សព្វផ្សាយ ដែលរួមមានទូរទស្សន៍ទាំងអស់ និងវិទ្យុភាគច្រើន។

ការចូលរួមរបស់ស្ត្រី និងក្រុមជនជាតិភាគតិច៖ វប្បធម៌ប្រពៃណីកម្រិតតួនាទីរបស់ស្ត្រីនៅក្នុងរដ្ឋាភិបាល ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីបានចូលរួមនៅក្នុងការបោះឆ្នោតជាតិ កាលពីខែកក្កដា ឆ្នាំ ២០១៣។ មានស្ត្រីចំនួន ២៥ នាក់កាន់កាប់អាសនៈសភាដែលមានចំនួន ១២៣ អាសនៈ និងមានស្ត្រីចំនួន ១០ នាក់ទៀតនៅក្នុងព្រឹទ្ធសភាដែលមាន៦១ អាសនៈ។ មានឧបនាយករដ្ឋមន្ត្រីម្នាក់ជាស្ត្រី និងមានស្ត្រីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការចំនួន ៨០ នាក់។ ស្ត្រីក៏បានបំពេញ តួនាទីជាទីប្រឹក្សាផងដែរ ហើយមានចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រីចំនួន ៥២ នាក់នៅតុលាការរាជធានី តុលាការខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ ទោះបីជាគ្មានអភិបាលខេត្តជាស្ត្រីក៏ដោយ ក៏រដ្ឋាភិបាលបានតែងតាំងស្ត្រីជាអភិបាលរងខេត្តនៅគ្រប់ខេត្តក្រុងទាំង ២៤ រួមនឹងរាជធានាភ្នំពេញផងដែរ ។ គណៈកម្មការជាតិរៀបចំការបោះឆ្នោតបានរាយការណ៍ថា ស្ត្រីបានកាន់កាប់ ១៧ ភាគរយនៃអាសនៈក្រុមប្រឹក្សាឃុំសង្កាត់ និង ១៣ ភាគរយនៃអាសនៈក្រុមប្រឹក្សាស្រុក និងខេត្ត ។

## ផ្នែកទី៤ ៖ អំពើពុករលួយ និងកង្វះតម្លាភាពក្នុងរដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌសម្រាប់អំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីនានា ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីប្រព្រឹត្តអំពើពុករលួយជាញឹកញាប់ ដោយមាននិទណ្ឌភាព ។ បានរបាយការណ៍ដោយឡែកៗស្តីពីអំពើពុករលួយក្នុងរដ្ឋាភិបាល នៅក្នុងឆ្នាំនៃរបាយការណ៍នេះ។

អំពើពុករលួយ៖ ក្រមព្រហ្មទណ្ឌបានកំណត់អំពើពុករលួយនានា ហើយកំណត់ច្បាស់នូវទោសចំពោះការប្រព្រឹត្តអំពើទាំងនេះ។ ច្បាប់ប្រឆាំងអំពើពុករលួយចែងពីមូលដ្ឋានច្បាប់សំរាប់អោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយទទួល និងស៊ើបអង្កេតបណ្តឹងទាក់ទងនឹងអំពើពុក

រលួយ។ អង្គភាពប្រឆាំងអំពើពុករលួយមិនសហការអោយបានញឹកញាប់ជាមួយសង្គមស៊ីវិល ខ្វះធនធានគ្រប់គ្រាន់ ហើយត្រូវបានគេមើលឃើញថា គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

អំពើពុករលួយមានលក្ខណៈរាលដាល និងរាលដាលនៅគ្រប់ផ្នែកនៃសង្គម រួមទាំងផ្នែកនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការនៃរដ្ឋាភិបាល ។ មានសេចក្តីរាយការណ៍មកថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជំរះក្តី បានទទួលសំណូកពីអ្នករកស៊ីខុសច្បាប់។ សាធារណជនបានត្អូញត្អែរញឹកញាប់ និងជាសាធារណៈ អំពីអំពើពុករលួយ ដែលជាការបង្ហាញអោយឃើញថា អំពើពុករលួយជាច្រើនពុំមានការលាក់លៀមឡើយ ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកអោយ មាន"អំពើពុករលួយដើម្បីរស់"  ក្នុងចំណោមមន្ត្រីថ្នាក់ទាប ចំណែកវប្បធម៌និទណ្ឌភាពធ្វើអោយអំពើពុករលួយរីកសាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។

ការបង្ហាញផ្នែកហិរញ្ញវត្ថុ៖ រាជការ រួមទាំងមន្ត្រីតែងតាំង និងមន្ត្រីជាប់ឆ្នោតផង តាមច្បាប់ត្រូវប្រកាសទ្រព្យសម្បត្តិរបស់គេ។ អង្គភាពប្រឆាំងអំពើពុករលួយទទួលខុសត្រូវក្នុងការទទួលយកសេចក្តីប្រកាស ចំណែកការពិន័យចំពោះការមិនគោរពតាមមានការជាប់ពន្ធនាគាររាប់ពី ១ ខែទៅ ១ ឆ្នាំ។ កូននៅក្នុងបន្ទុក និងភរិយាឬប្តីមិនស្ថិតក្រោមច្បាប់តំរូវអោយប្រកាសទ្រព្យសម្បត្តិទេ។

លទ្ធភាពរបស់សាធារណជនចំពោះការទទួលព័ត៌មាន៖ ច្បាប់ស្តីពីបណ្ណាសារជាតិ (National Archives Law) អនុញ្ញាតអោយគេមើលឯកសារព័ត៌មានដោយគ្មានកំណត់ នៅក្នុងបណ្ណាសារសាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះផ្តល់លទ្ធភាពអោយមើលឯកសាររដ្ឋាភិបាលដែលមិនត្រូវបានបញ្ជាក់ច្បាស់ តែក្នុងរយៈ ២០ ឆ្នាំក្រោយមកតែប៉ុណ្ណោះ ចំណែកឯកសារប៉ះពាល់ដល់សន្តិសុខជាតិ និងការពារជីវិតផ្ទាល់ខ្លួនអាចបញ្ចេញអោយបានបន្ទាប់ពីរយៈពេល ៤០ឆ្នាំ និង ១២០ ឆ្នាំក្រោយមកតែប៉ុណ្ណោះ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា តាមការជាក់ស្តែង  ខ្លួនមានការលំបាកក្នុងការសុំបានព័ត៌មានមកមើល។  រដ្ឋាភិបាល ជាញឹកញាប់ មិនបានឆ្លើយតបចំពោះសំណើសុំព័ត៌មានទេ ។

## ផ្នែកទី៥ ៖ ឥរិយាបថរបស់រដ្ឋាភិបាលចំពោះការស៊ើបអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើការចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្ស

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិផ្សេងៗ ជាទូទៅ ធ្វើប្រតិបត្តិការដោយគ្មានការរឹតត្បិតពីរដ្ឋាភិបាលឡើយ ក្នុងការស៊ើបអង្កេត និងបោះពុម្ពផ្សាយរបកគំហើញអំពីករណីសិទ្ធិមនុស្សរបស់ខ្លួន ។ ជា

រឿយៗ មន្ត្រីរដ្ឋាភិបាលបានសហការជាមួយបុគ្គលិកសិទ្ធិមនុស្សក្នុងការស៊ើបអង្កេតរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ មានរបាយការណ៍ជាច្រើនអំពីកង្វះការសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័យដោយមន្ត្រីរដ្ឋាភិបាល ។

មានអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្សប្រមាណជា ៤០ នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែមានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិជួបប្រទះការគម្រាមកំហែង និងការធ្វើទុក្ខបុកម្នេញពីមន្ត្រីមូលដ្ឋាន ។ អំពើទាំងនេះមានលក្ខណៈជាទម្រង់រឹតត្បិត និងការរំខានដល់ការជួបប្រជុំដែលឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាលនានា ការបំភិតបំភ័យដោយពាក្យសម្តី ការគម្រាមចាត់វិធានការផ្លូវច្បាប់ និងការរារាំងតាមបែបការិយាធិបតេយ្យ ។

<u>អង្គការសហប្រជាជាតិ ឬអង្គការអន្តរជាតិដទៃទៀត</u>៖រដ្ឋាភិបាលជាទូទៅបានសហការជាមួយអង្គការអន្តរជាតិហើយបានអនុញ្ញាតអោយតំណាងអង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ច ។ អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក Surya Subedi បានមកធ្វើទស្សនកិច្ចនៅកម្ពុជាចំនួន ២ ដង ។ នៅខែមករា លោកបានជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋមន្ត្រីមួយចំនួនទៀតរបស់រដ្ឋាភិបាល ដោយរួមទាំងលោក ឱម យិនទៀង ប្រធានគណកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ ក្នុងអំឡុងទស្សនកិច្ចរបស់លោក លោកបានជួបជាមួយលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃស ខេង និងសមាជិកជាន់ខ្ពស់ដទៃទៀតនៃរដ្ឋាភិបាល។ នៅក្នុងអំឡុងពេលនៃទស្សនកិច្ចទាំងពីរលើករបស់លោក លោកបានជួបជាមួយនឹងអង្គការសង្គមស៊ីវិល និងមេដឹកនាំគណបក្សប្រឆាំង។

<u>ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល៖</u> រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួន ៣ ដែលរួមមានគណៈកម្មាធិការដាច់ដោយឡែកចំនួន ២ ទទួលបន្ទុកការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង ដោយស្ថាប័នមួយស្ថិតក្រោមព្រឹទ្ធសភា និងមួយទៀតស្ថិតក្រោមរដ្ឋសភា ព្រមទាំងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលស្ថិតនៅក្រោមខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការទាំងនេះពុំមានការប្រជុំទៀងទាត់ ឬដំណើរការប្រកបដោយតម្លាភាពឡើយ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាប្រគល់របាយការណ៍របស់រដ្ឋាភិបាល ដើម្បីចូលរួមក្នុងដំណើរការពិនិត្យសិទ្ធិមនុស្សជាអន្តរជាតិ ដូចជាការពិនិត្យទៀងទាត់ជាសកល និងបានឆ្លើយតបចំពោះ

របាយការណ៍របស់ស្ថាប័នរដ្ឋាភិបាលអន្តរជាតិ ប៉ុន្តែមិនបានធ្វើការស៊ើបអង្កេតស្ថានភាពសិទ្ធិមនុស្សដោយឯករាជ្យឡើយ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលគួរឱ្យទុកចិត្តបាន ចាត់ទុកសមត្ថភាពរបស់គណៈកម្មាធិការរបស់រដ្ឋាភិបាលថា មានកម្រិត។

រដ្ឋាភិបាលបានធ្វើជាម្ចាស់ផ្ទះសម្រាប់អង្គជំនុំជម្រះក្តួនកាត់ វិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) ដែលដំណើរការរួមគ្នាជាមួយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពាននៅសម័យខ្មែរក្រហម។ អ្នកសង្កេតការណ៍ខ្លះមានជំនឿថា សេចក្តីអត្ថាធិប្បាយជាសាធារណៈរបស់អ្នកដឹកនាំរដ្ឋាភិបាលអំពីបញ្ហាទាក់ទងនឹងអាណត្តិយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាគឺជាទម្រង់មួយនៃការជ្រៀតជ្រែករបស់អ្នកនយោបាយ ។ ទោះជាយ៉ាងណាក៏ដោយ គ្មានភស្តុតាងដែលបង្ហាញថា សេចក្តីអត្ថាធិប្បាយទាំងនោះ បានរាំងស្ទះដល់ការងាររបស់តុលាការឡើយ។

នៅថ្ងៃទី ៧ ខែសីហា ECCC បានប្រកាសសាលក្រមអោយជាប់ទោសទៅលើករណី 00២ ប្រឆាំងនឹងអតីតមេដឹកនាំខ្មែរក្រហម គឺ "បងធំទី ២" ឈ្មោះ នួន ជា និងអតីតប្រមុខរដ្ឋ ឈ្មោះខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការកាប់សំលាប់ ការធ្វើទុក្ខផ្នែកនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតទាក់ទងនឹងការបង្ខំអោយប្រជាជនតំបន់ក្រុងទៅរស់នៅតាមជនបទ ព្រមទាំងការកាប់សំលាប់មន្ត្រីសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃ។ តុលាការបានដាក់ទោសអោយជនទាំងពីរនេះជាប់ពន្ធនាគារអស់មួយជីវិត។ បន្ទាប់មក តុលាការនឹងបើកសវនាការលើការចោទប្រកាន់លើបទឧក្រិដ្ឋបន្ទាប់ទៀតរបស់របបនេះ ដែលរួមមានអំពើប្រល័យពូជសាសន៍លើក្រុមជនជាតិចាមភាគតិច ការបង្ខំអោយរៀបអាពាហ៍ពិពាហ៍ ការរំលោភផ្លូវភេទ ការធ្វើវិសុទ្ធកម្មផ្ទៃក្នុង និងការចោទប្រកាន់លើបទឧក្រិដ្ឋដែលប្រព្រឹត្តនៅតាមមជ្ឈមណ្ឌលសន្តិសុខ និងការដ្ឋានខ្លះ។

**ផ្នែកទី៦៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស**

រដ្ឋធម្មនុញ្ញហាមប្រាម

អំពើរំលោភសេពសន្ថវ: និងអំពើហិង្សាក្នុងគ្រួសារ៖ ច្បាប់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើរំលោភសេពសន្ថវ: និងការបំពារបំពាន។ ទោះជាយ៉ាងនេះក្តី អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិបានរាយការណ៍ថា អំពើហិង្សាប្រឆាំងស្ត្រី មានដូចជាអំពហឹង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវ: កើតមានជាទូទៅ។ អំពើរំលោភសេពសន្ថវ:ត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ។ អំពើរំលោភសេពសន្ថវ: ប្តី/ប្រពន្ធមិនត្រូវបានចែងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌឡើយ ប៉ុន្តែ អាចធ្វើការចោទប្រកាន់ថាជា "អំពើរំលោភសេពសន្ថវ:" "ការបង្ករបួសស្នាម" ឬ "ការបំពារបំពានមិនសមរម្យ"បាន។ យោងតាមច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវ:ប្តី/ប្រពន្ធអាចស្ថិតនៅក្នុងនិយមន័យនៃអំពើហិង្សាក្នុងគ្រួសារ ដែលរួមបញ្ចូល "ការបំពានផ្លូវភេទ" ផងដែរ។ កម្រមានការចោទប្រកាន់ពីបទរំលោភសេពសន្ថវ: ប្តី/ប្រពន្ធតាមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារណាស់។ គេអាចប្រើក្រមព្រហ្មទណ្ឌ ដើម្បីដាក់ទោសចំពោះបទល្មើសហឹង្សាក្នុងគ្រួសារ ដោយដាក់ទោសពន្ធនាគារចាប់ពី ១ ឆ្នាំរហូតដល់ ១៥ឆ្នាំ។ នៅក្នុងរបាយការណ៍ឆ្នាំ ២០១៣ របស់អង្គការសហប្រជាជាតិ ជិត ២០% នៃបុរសចំនួន ១៨៦៣នាក់ ដែលត្រូវបានសំភាសន៍ បានសារភាពថា បានរំលោភសេពសន្ទវ:លើស្ត្រី។

អង្គការមិនមែនរដ្ឋាភិបាលមួយ ឈ្មោះអាដហុកបានទទួលរបាយការណ៍អំពីករណីរំលោភសេពសន្ថវ:ចំនួន ៨១ ករណី ដោយគិតត្រឹមខែមិថុនា ។ នៅក្នុងចំណោមករណីទាំងនេះ មាន ១២ ករណីត្រូវបានកាត់ក្តីដោយតុលាការ ១ ករណីត្រូវបានសម្របសម្រួលដោយអាជ្ញាធរមូលដ្ឋាន ហើយករណីនៅសល់ត្រូវរង់ចាំសវនាការ ។ ចំពោះអំពើហិង្សាក្នុងគ្រួសារ អង្គការអាដហុកបានរាយការណ៍ថា មាន ៥៦ ករណី ដោយគិតត្រឹមខែមិថុនា។ អង្គការមិនមែនរដ្ឋាភិបាលមួយផ្សេងទៀតបានចងក្រងអំពើហិង្សាក្នុងគ្រួសារថាមានចំនួន ៧១ ករណី នៅក្នុងរយ:ពេលដដែលនោះ។ ក្នុងរបាយការណ៍របស់អង្គការមួយនេះ ករណីហឹង្សាក្នុងគ្រួសារចំនួន ២ ករណីបានបណ្តាលអោយជនរងគ្រោះម្នាក់ស្លាប់ក្នុងមួយករណីៗ។ ពិតមែនតែទំនងជាមានការរាយការណ៍មិនគ្រប់អំពីបញ្ហាហឹង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវ: ដោយសារស្ត្រីមានការភ័យខ្លាចចំពោះការសងសឹកពីជនល្មើសក្តី តែមាននិន្នាការថយចុះពីឆ្នាំមុនៗ។

រដ្ឋាភិបាលបានគាំទ្រអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីក្រីក្រ ងាយរងគ្រោះពីការរំលោភពីប្តី ពីពេស្យាចារ្យ និងពីការជួញដូរ។ ក្រសួងកិច្ចការនារីបានសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយ និងប្រព័ន្ធផ្សព្វផ្សាយមួយក្នុងស្រុក ដើម្បីបង្កើតកម្មវិធីចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍អំពីបញ្ហាស្ត្រី។

ការកាត់ប្រដាប់បន្តពូជរបស់ស្ត្រីនិងកុមារីៈ គ្មានច្បាប់ហាមប្រាមលើការកាត់ប្រដាប់បន្តពូជរបស់ស្ត្រីនិងកុមារីទេ តែក៏គ្មានសេចក្តីរាយការណ៍មកពីទង្វើបែបនេះដែរ។

<u>ការបៀតបៀនផ្លូវភេទៈ</u> ក្រមព្រហ្មទណ្ឌដាក់ទោសព្រហ្មទណ្ឌចំពោះការបៀតបៀនផ្លូវភេទ ដោយដាក់ពន្ធនាគារពី ៦ ថ្ងៃទៅ ៣ ខែ និងពិន័យជាទឹកប្រាក់ចំនួនពី ១០០ ០០០រៀលទៅ ៥០០ ០០០រៀល (២៥ ទៅ ១២៥ ដុល្លារអាមេរិក)។ ប៉ុន្តែ មិនមានការចាប់ខ្លួន ឬកាត់ទោសឡើយ។ រដ្ឋាភិបាលធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈដែលផ្តោតជាក់លាក់លើស្ត្រីលក់ស្រាបៀរនៅកន្លែងកម្សាន្តដែលបានរាយការណ៍ថា ងាយរងគ្រោះដោយសារការបៀតបៀន។ ពុំទាន់មានព័ត៌មានអំពីអត្រានៃការកើតមានបទល្មើសនេះនៅឡើយទេ។

<u>សិទ្ធិបន្តពូជៈ</u> គូស្វាមី ភរិយា និងបុគ្គលម្នាក់ៗអាចសម្រេចចិត្តដោយសេរី និងដោយមានការទទួលខុសត្រូវចំពោះចំនួនកូនដែលចង់បាន គម្លាតមានកូន និងពេលមានកូន ហើយពួកគេមានព័ត៌មាន និងមធ្យោបាយដើម្បីទទួលបានបទដ្ឋានខ្ពស់បំផុតនៃសុខភាពបន្តពូជ ដោយគ្មានការរើសអើង ការបង្ខំ និងដោយគ្មានហឹង្សា។ ស្ត្រីមានសិទ្ធិទទួលសេវាពន្យារកំណើត និងការថែទាំមុនពេលសម្រាល ព្រមទាំងឆ្មបមានជំនាញ និងការថែទាំក្រោយពេលសម្រាលផងដែរ ប៉ុន្តែជារឿយៗ សិទ្ធិនេះនៅមានកម្រិត ដោយសារឧបសគ្គប្រាក់ចំណូល និងទីតាំងភូមិសាស្ត្រ។ យោងតាមការអង្កេតរបស់មូលនិធិប្រជាជនរបស់សហប្រជាជាតិ អត្រាមរណៈមាតានៅឆ្នាំ២០១៣ មានចំនួន ១៧០ នាក់ក្នុងទារកកើតរស់ចំនួន ១០០ ០០០នាក់។ កត្តាចម្បង ដែលមានឥទ្ធិពលលើអត្រាមរណៈមាតាខ្ពស់នៅក្នុងប្រទេសរួមមានកង្វះមណ្ឌលសុខភាពត្រឹមត្រូវ ថ្នាំសង្កូវ និងកង្វះឆ្មបមានជំនាញត្រឹមត្រូវ។ អត្រាប្រេវ៉ាឡង់នៃការប្រើមធ្យោបាយពន្យាកំណើតក្នុងចំណោមស្ត្រីមានប្តី ដែលស្ថិតក្នុងអាយុពី ១៥ ឆ្នាំដល់ ៤៩ ឆ្នាំគឺមានប្រហែល ៣៥ ភាគរយ។

<u>ការរើសអើងៈ</u> រដ្ឋធម្មនុញ្ញចែងអំពីសិទ្ធិស្មើភាពគ្នាសំរាប់ស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា និងឋានៈស្មើគ្នាក្នុងអាពាហ៍ពិពាហ៍។ ជាទូទៅ ស្ត្រីមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នា មានសិទ្ធិតាមផ្លូវច្បាប់ដូចគ្នាក្នុងការដាក់ពាក្យបណ្តឹងលែងលះ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ និងការងារមួយចំនួន។ ប៉ុន្តែ ប្រពៃណីវប្បធម៌ និងការទទួលខុសត្រូវក្នុងការថែរក្សាកូនបានកម្រិតសមត្ថភាពរបស់ស្ត្រីក្នុងការឈានទៅដល់ការទទួលបានមុខតំណែងខ្ពស់នៅក្នុងការងារ ឬចូលរួមក្នុងកំលាំងការងារ ។ បុរសយ៉ាងច្រើនលើសលុបបម្រើការងារយោធា នគរបាល និងការងាររាជការស៊ីវិល។

ក្រសួងកិច្ចការនារី ដែលត្រូវបានផ្តល់អាណត្តិអោយការពារសិទ្ធិស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គម បានបន្តកម្មវិធី នារីរតនៈ (“ស្ត្រីជាត្បូងពេជ្រដ៏មានតម្លៃ”)។ កម្មវិធីនេះមានគោលបំណងលើកកម្ពស់មុខមាត់ស្ត្រីតាមរយៈការបញ្ជ្រាបយេនឌ័រ ជំរុញឱ្យស្ត្រីចូលរួមនៅក្នុងជីវិតសេដ្ឋកិច្ច និងនយោបាយ និង ការពារសិទ្ធិស្ត្រី។ មន្ទីរ ក្រសួងរដ្ឋាភិបាលចំនួន ២៨ បានបន្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រដោយមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី។

## កុមារ

<u>ការចុះសំបុត្រកំណើត៖</u> តាមច្បាប់ សញ្ជាតិអាចទទួលបានតាមរយៈកំណើតពីឪពុកនិងម្តាយដែលមិនមែនជាជនជាតិខ្មែរ ក្នុងករណីដែលឪពុកម្តាយទាំងពីរនោះបានកើត និងរស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ឬករណីដែលឪពុក/ម្តាយណាម្នាក់ទទួលបានសញ្ជាតិកម្ពុជា។ ខ្មែរជនជាតិត្រូវបានចាត់ទុកជាពលរដ្ឋខ្មែរ។ ក្រសួងមហាផ្ទៃបានគ្រប់គ្រងប្រព័ន្ធចុះបញ្ជីកំណើតតាមបែបទំនើប ប៉ុន្តែ ទារកទាំងអស់មិនសុទ្ធតែត្រូវបានចុះបញ្ជីភ្លាមៗឡើយ ដោយសារតែឪពុកម្តាយពន្យារពេល។ ប្រព័ន្ធនេះមិនបានដាក់បញ្ចូលសេវាពិសេស សំរាប់សហគមន៍ភាគតិចឡើយ។ ក្រៅពីនេះ កុមារដែលបានកើតចាប់ពីពាក់កណ្តាលទសវត្សឆ្នាំ១៩៧០ ដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ជាទូទៅ មិនត្រូវបានចុះបញ្ជីកំណើតឡើយ ដោយសារការគ្រប់គ្រងរបស់វៀតណាម/ខ្មែរក្រហម/សង្គ្រាមស៊ីវិល។ អ្នកដែលមិនបានចុះបញ្ជីទាំងនេះជាច្រើន ដែលក្រោយមកមាន គ្រួសារផ្ទាល់ខ្លួន មិនបានយល់អំពីភាពចាំបាច់នៃការចុះបញ្ជីនេះទេ។ ជាទូទៅ យុវជនមិនទៅចុះបញ្ជីកំណើតឡើយ រហូតទាល់តែគេត្រូវការចាំបាច់។

ការខកខានមិនបានចុះបញ្ជីកំណើតនាំអោយមានការរើសអើង រួមទាំងការមិនផ្តល់សេវាសាធារណៈផង។ ការសិក្សាមួយនៅឆ្នាំ ២០០៧ ដែលធ្វើឡើងដោយអង្គការ UNHCR ស្តីពីភាពគ្មានសញ្ជាតិនៅក្នុងប្រទេសកម្ពុជាបាននិយាយថា ជារឿយៗ កុមារនៃជនជាតិភាគតិច និងអ្នកគ្មានសញ្ជាតិត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីកំណើត។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាចំពោះសហគមន៍ដែលត្រូវបានគេផាត់ចេញ បានរាយការណ៍ថា ជារឿយៗ កុមារដែលគ្មានសំបុត្រកំណើត និងសៀវភៅគ្រួសារ បាត់បង់លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះក៏បានបញ្ជាក់ផងដែរថា ទៅថ្ងៃអនាគត កុមារទាំងនេះអាចមិនមានលទ្ធភាពទទួលបានការងារធ្វើ មានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចូលរួមបោះឆ្នោត ឬប្រើប្រាស់ប្រព័ន្ធច្បាប់នោះទេ។

ការអប់រំ៖ កុមារទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារប្រព័ន្ធអប់រំដែលគ្មានលក្ខណៈគ្រប់គ្រាន់។ ការអប់រំរហូតដល់ថ្នាក់ទី៩ គឺឥតមានបង់ថ្លៃឡើយ ប៉ុន្តែ មិនមែនជាកាតព្វកិច្ចទេ។ កុមារជាច្រើនបានឈប់រៀនដើម្បីជួយគ្រួសារក្នុងការងារកសិកម្មលក្ខណៈគ្រួសារ ធ្វើការងារនៅក្នុងសកម្មភាពផ្សេងទៀត ចូលរៀននៅអាយុច្រើន ឬមិនចូលរៀនសោះតែម្តង។ រដ្ឋាភិបាលមិនបដិសេធក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នាទេ។ ប៉ុន្តែ ជារឿយៗ គ្រួសារដែលមានធនធានមានកំរិត ផ្តល់អាទិភាពដល់ក្មេងប្រុសជាងក្មេងស្រី។ បើយោងតាមរបាយការណ៍អង្គការអន្តរជាតិ បន្ទាប់ពីកម្រិតបឋមសិក្សា ចំនួនក្មេងស្រីចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំង។ សាលារៀននៅក្នុងតំបន់ជាច្រើនស្ថិតនៅឆ្ងាយពីផ្ទះ ហើយការធ្វើដំណើរក៏ជាបញ្ហាមួយផងដែរ។ កត្តានេះបានធ្វើឱ្យប៉ះពាល់ដល់ក្មេងស្រីជាពិសេស ដោយសារកង្វល់ពីសុវត្ថិភាពក្នុងការធ្វើដំណើរពីផ្ទះទៅសាលារៀន។

អំពើពុករលួយនៅក្នុងប្រព័ន្ធអប់រំក៏ធ្វើអោយមានផលប៉ះពាល់មិនល្អផងដែរ។ នៅពេលក្រសួងអប់រំចាត់វិធានការការពារកុំអោយមានអំពើពុករលួយ និងការលួចចំលង នៅក្នុងការប្រលងថ្នាក់ជាតិបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ មានសិស្សចំនួន ៧៥% បានប្រលងធ្លាក់។ នេះបើតាមសេចក្តីរាយការណ៍ក្នុងសារព័ត៌មាន។

ការធ្វើបាបកុមារ៖ អ្នកសង្កេតការណ៍ចាត់ទុកថាការធ្វើបាបកុមារមានជាទូទៅ ទោះបីគ្មានស្ថិតិបញ្ជាក់ក្តី។ ការរំលោភសេពសន្ថវៈលើកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរមួយនៅឡើយ។ អង្គការមិនមែនរដ្ឋាភិបាល ADHOC បានរាយការណ៍ ថា ករណីរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈចំនួន ៦០ ករណីបានកើតឡើងចំពោះកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ។

អាពាហ៍ពិពាហ៍ដោយបង្ខំ និងក្នុងវ័យក្មេង៖ អាយុគ្រប់ការតាមច្បាប់សំរាប់ក្មេងប្រុស និងក្មេងស្រីគឺ ១៨ ឆ្នាំ។ នៅឆ្នាំ ២០១២ ១៨% នៃនារីដែលមានអាយុពី ២០ ទៅ ២៤ ឆ្នាំ បានរៀបការនៅពេលគេមានអាយុក្រោម ១៨ ឆ្នាំ។ តាមវប្បធម៌ខ្មែរ ការរៀបការកុមារមិនត្រូវបានចាត់ទុកថាជាបញ្ហាទេ ។រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលខ្មែរមួយបានប្រកាន់ជំហានលើកកំពស់ការយល់ដឹងលើការតំរូវលើអាយុអប្បបរិមាដូចដែលត្រូវបានកំណត់ដោយច្បាប់។

ការកាត់ប្រដាប់បន្តពូជរបស់ស្ត្រីនិងកុមារី៖ គ្មានច្បាប់ហាមប្រាមលើការកាត់ប្រដាប់បន្តពូជរបស់ស្ត្រីនិងកុមារីទេ តែក៏គ្មានសេចក្តីរាយការណ៍មកពីទង្វើបែបនេះដែរ។

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ៖ ការរួមភេទជាមួយកុមារអាយុក្រោម ១៥ ឆ្នាំ គឺជាអំពើខុសច្បាប់។ នៅអំឡុងឆ្នាំនៃរបាយការណ៍ នគរបាលបានវាយឆ្មក់ចូលផ្ទះបន ហើយបានជួយសង្គ្រោះក្មេងស្រីមិនគ្រប់អាយុ ដែលត្រូវបានគេជួញដូរអោយធ្វើពេស្យា។ គិតមកត្រឹមខែមិថុនា ក្រសួងមហាផ្ទៃបានរាយការណ៍ថា អាជ្ញាធរបានចាប់ខ្លួនជនបរទេសចំនួន ៣ នាក់ ពីបទរួមភេទជាមួយកុមារ។ កុមារមួយចំនួនបានធ្វើពេស្យាដើម្បីចិញ្ចឹមជីវិត ដោយគ្មានការពាក់ព័ន្ធរបស់ភាគីទីបីឡើយ។ រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដើម្បីកាត់ទោសអ្នកទេសចរផ្លូវភេទ ដែលរំលោភបំពានលើកុមារ។

ច្បាប់ស្តីពីការជួញដូរមនុស្សដាក់ទោសចំពោះការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដោយដាក់ពន្ធនាគារចាប់ពី ២ ទៅ ១៥ ឆ្នាំ។ ច្បាប់នេះក៏ហាមប្រាមរូបអាសអាភាសរបស់កុមារផងដែរ។

កុមារផ្លាស់ទីលំនៅ៖ រដ្ឋាភិបាលបានផ្តល់សេវាមានកំរិត និងមិនគ្រប់គ្រាន់ដល់កុមាររស់នៅតាមចិញ្ចើមថ្នល់ នៅមជ្ឈមណ្ឌលស្តារនីតិសម្បទា។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានវាយតម្លៃថា មានកុមារតាមចិញ្ចើមផ្លូវប្រមាណពី ១២០០ ទៅ ១៥០០ នាក់នៅក្នុងរាជធានីភ្នំពេញ ដែលគ្មានទំនាក់ទំនងជាមួយគ្រួសារ ហើយមានកុមារប្រមាណជាពី ១៥ ០០០ ទៅ ២០ ០០០នាក់ បានធ្វើការងារនៅតាមចិញ្ចើមផ្លូវ ប៉ុន្តែ បានត្រឡប់ទៅផ្ទះវិញនៅពេលយប់។ កុមារប្រមាណជា ២០០ ទៅ ៤០០ នាក់ បានរស់នៅជាមួយគ្រួសាររបស់ខ្លួននៅតាមចិញ្ចើមផ្លូវនៃរាជធានីភ្នំពេញ។

កុមារក្នុងពន្ធនាគារ៖ ក្រសួងមហាផ្ទៃបានរាយការណ៍ថា ដោយគិតមកត្រឹមខែមិថុនា យ៉ាងហោចណាស់ មានកុមារក្រោមអាយុ ៦ ឆ្នាំចំនួន ៣៤ នាក់ ត្រូវបានគេរាយការណ៍ថា កំពុងរស់នៅជាមួយម្តាយរបស់ខ្លួន នៅក្នុងពន្ធនាគារ។ អង្គការមិនមែនរដ្ឋាភិបាលមួយក្នុងស្រុកបានរាយការណ៍ថា មានកុមារបែបនេះចំនួន ៣៧ នាក់ រស់នៅក្នុងពន្ធនាគារចំនួន១៩  និងបានអះអាងថា កុមារទាំងនេះទទួលបានការមើលថែមិនបានល្អពីឆ្មាំពន្ធនាគារ និងប្រឈមមុខនឹងគ្រោះថ្នាក់លើរាងកាយពីអ្នកទោសព្រហ្មទណ្ឌដែលជាមនុស្សពេញវ័យ ដែលត្រូវបានដាក់នៅក្នុងកន្លែងជាមួយ។ ជាទូទៅ កុមារទាំងនេះខ្វះអាហារូបត្ថម្ភ និងការអប់រំគ្រប់គ្រាន់។

ការចាប់ជំរិតកុមារឆ្លងដែន៖ ប្រទេសកម្ពុជាមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទិដ្ឋភាពស៊ីវិលនៃការចាប់ជំរិតកុមារឆ្លងដែនឡើយ។

ការប្រឆាំងនឹងសាសនាជ្វីស (Anti-Semitism)

មានសហគមន៍អនិកជនកាន់សាសនាជ្វីសតូចមួយនៅក្នុងរាជធានីភ្នំពេញ ហើយមិនមានរបាយការណ៍អំពីទង្វើប្រឆាំងនឹងពួកនេះឡើយ។

## ការជួញដូរមនុស្ស

សូមចូលមើល *របាយការណ៍ស្តីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gov/j/tip/rls/tiprpt/ ។

## ជនពិការ

ច្បាប់ហាមឃាត់ការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ។ នៅក្នុងច្បាប់នេះ និយមន័យជនពិការរួមបញ្ចូលទាំងជនដែលមានជំងឺសតិស្មារតី និងជនពិការប្រាជ្ញាផងដែរ ហើយច្បាប់នេះក៏តម្រូវផងដែរថា អាគារសាធារណៈ និងទីតាំងផ្តល់សេវារដ្ឋាភិបាល រួមទាំងគ្រឹះស្ថានអប់រំផងដែរ ត្រូវមានមធ្យោបាយដែលអាចឱ្យជនពិការចេញចូលបាន។ ច្បាប់នេះមិននិយាយពីមធ្យោបាយចេញចូល ឬឡើងចុះ ពេលធ្វើដំណើរតាមយន្តហោះ ឬធ្វើដំណើរតាមមធ្យោបាយផ្សេងឡើយ។ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវរួមលើការការពារសិទ្ធិជនពិការ ថ្វីបើច្បាប់នេះកំណត់ភារកិច្ចជាក់លាក់សំរាប់បណ្តាក្រសួងផ្សេងទៀត ដូចជា ក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងសាធារណៈការ និងដឹកជញ្ជូន និងក្រសួងការពារជាតិក្តី។ រដ្ឋាភិបាលបានស្នើឱ្យបណ្តាញទូរទស្សន៍ទាំងអស់ប្រើប្រាស់ការបកប្រែភាសាសញ្ញាក្នុងកម្មវិធីរបស់ខ្លួន។ គិតត្រឹមខែសីហា ស្ថានីយទូរទស្សន៍ធំជាងគេមួយមានការបកប្រែភាសាសញ្ញា ហើយក្រសួងព័ត៌មានកំពុងធ្វើការងារជាមួយនឹងស្ថានីយទូរទស្សន៍ផ្សេងៗទៀត ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការបកប្រែភាសាសញ្ញានេះ។ រដ្ឋាភិបាលបានបន្តការខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តច្បាប់នេះ ទោះបីជារយៈពេលពេញលេញសម្រាប់អនុវត្តច្បាប់នៅក្នុងករណីមួយចំនួនអាចពន្យារដល់ឆ្នាំ២០១៥ ក៏ដោយ។ ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តអនុក្រឹត្យចំនួន ៤ ដើម្បីគាំទ្រច្បាប់នេះ។

កម្មវិធីដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលនានា បានធ្វើការកែលម្អគួរឱ្យកត់សម្គាល់ចំពោះការប្រព្រឹត្ត និងការស្តារនីតិសម្បទាលើជនពិការ ប៉ុន្តែ ពួកគាត់បានប្រឈមនឹងការរើសអើងពីសង្គមយ៉ាងច្រើន ជាពិសេសលទ្ធភាពក្នុងការទទួលបានការងារជំនាញ។

កុមារដែលពិការមិនធ្ងន់ធ្ងរអាចចូលសាលាបាន។ កុមារដែលមានភាពពិការច្រើន រៀននៅសាលាដាច់ដោយឡែក ដែលឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាល នៅភ្នំពេញ។ យោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ ការអប់រំសំរាប់កុមារពិការធ្ងន់ធ្ងរគ្មាននៅក្រៅក្រុងភ្នំពេញទេ។

គ្មានការដាក់កំហិតផ្លូវច្បាប់លើសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមនៅក្នុងកិច្ចការស៊ីវិលឡើយ ប៉ុន្តែ រដ្ឋាភិបាលមិនបានខិតខំប្រឹងប្រែងសហការ ដើម្បីជួយពួកគាត់ឱ្យមានការចូលរួមក្នុងកិច្ចការស៊ីវិលបានច្រើនឡើយ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានទំនួលខុសត្រូវក្នុងការបង្កើតគោលនយោបាយ ដើម្បីការពារសិទ្ធិ និងស្តារនីតិសម្បទាជនពិការ ក៏ដូចជាផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់ពួកគាត់។

## សញ្ជាតិ/ពូជសាសន៍/ជនជាតិដើមភាគតិច

ច្បាប់ស្តីពីសញ្ជាតិមិនមានចែងច្បាស់លាស់អំពីសិទ្ធិរបស់ជនជាតិដើមភាគតិចឡើយ។ ការការពារតាមរដ្ឋធម្មនុញ្ញនិយាយតែពី "ប្រជាជនខ្មែរ" តែប៉ុណ្ណោះ។ អាណិកជនចិន និងវៀតណាមគឺជាជនជាតិភាគតិចភាគច្រើនជាងគេ។ ជនជាតិចិនត្រូវបានទទួលយកនៅក្នុងសង្គម ប៉ុន្តែ មានការបន្តស្អប់ខ្ពើមចំពោះជនជាតិវៀតណាម ដែលត្រូវបានគេមើលឃើញថា ជាការគំរាមកំហែងចំពោះប្រទេសជាតិ និងវប្បធម៌។ ក្រុមមួយចំនួន រួមទាំងក្រុមអ្នកនយោបាយផង បានបន្តនិយាយប្រឆាំងនឹងជនជាតិវៀតណាមយ៉ាងខ្លាំងក្លា។ ក្រុមទាំងនេះបានត្អូញត្អែពីការគ្រប់គ្រងផ្នែកនយោបាយពីរដ្ឋាភិបាលវៀតណាមលើគណបក្សប្រជាជនកម្ពុជា បញ្ហាទន្ទ្រាននៅតាមតំបន់ព្រំដែន និងបញ្ហាជាច្រើនផ្សេងទៀត ដែលក្រុមទាំងនេះបានទំលាក់កំហុសទៅលើជនជាតិវៀតណាម យ៉ាងហោចណាស់ក៏ក្នុងចំណែកខ្លះដែរ។

នៅថ្ងៃទី ១៥ កុម្ភៈ បុរសមួយក្រុមបានវាយជនជាតិវៀតណាមអាយុ ២៨ ឆ្នាំម្នាក់ ឈ្មោះ Nguyen Yaing Ngoc អោយស្លាប់ នៅខ័ណ្ឌមានជ័យ ក្នុងរាជធានីភ្នំពេញ ក្រោយពីមានគ្រោះថ្នាក់ចរាចរបន្តិចបន្តួច ដែលបានរាលដាលដល់ការវាយគ្នា។ ក្រោយពីអ្នកឈរមើលម្នាក់បានស្រែកថា "យួន" ក្រុមនោះបានសំរុកមកវាយជនរងគ្រោះ។ បន្ទាប់មក នគរបាលបានចាប់ខ្លួនឈ្មោះ វន ចាន់វុធថា ចំពោះការញុះញង់អោយវាយសំលាប់ឈ្មោះ Gguyen ។ នៅថ្ងៃទី ៩ ខែមិថុនា បន្ទាប់ពីការធ្វើការស៊ើបអង្កេតចំនួន ៣ ខែមក តុលាការ

ក្រុងភ្នំពេញបានអោយឈ្មោះ វន ចាន់វុធថារួចខ្លួន ដោយសារហេតុផលគ្មានភស្តុតាងគ្រប់គ្រាន់សំរាប់ដាក់បន្ទុក។

## ជនជាតិដើមភាគតិច

ជាការជួយដល់ការខិតខំប្រឹងប្រែងរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងកិច្ចការពារទឹកដីដូនតា និងធនធានធម្មជាតិរបស់ខ្លួន រដ្ឋាភិបាលបានចេញប័ណ្ណកម្មសិទ្ធិដីរួមទៅអោយសហគមន៍ជនជាតិដើមចំនួន ៨ សហគមន៍ នៅខេត្តរតនៈគីរ និងខេត្តមណ្ឌលគីរី។ នៅឆ្នាំ ២០១៤ ក្រសួងរៀបចំដែនដីបានពិនិត្យសំរេចលើប័ណ្ណកម្មសិទ្ធិដីបន្ថែម សំរាប់សហគមន៍ជនជាតិដើមចំនួន ៧ ទៀត នៅខេត្តមណ្ឌលគីរី ក្រចេះ និងរតនគីរី។ អង្គការមិនមែនរដ្ឋាភិបាលបានរិះគន់យូរមកហើយនូវដំណើរការអនុវត្តយឺតៗនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីរួមហើយបានបន្តសុំអោយមានការផ្អាកការលក់ដី និងការផ្តល់សម្បទានដីដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិមានសកម្មភាពយ៉ាងសកម្មក្នុងការអប់រំសហគមន៍ជនជាតិដើមភាគតិចអំពីដំណើរការចុះបញ្ជីដី ព្រមទាំងផ្តល់ជាតំណាងផ្នែកច្បាប់ក្នុងវិវាទផងដែរ។

## អំពើហឹង្សា ការរើសអើង និងការរំលោភដទៃទៀត ដោយហេតុផលផ្លូវភេទ និងអត្តសញ្ញាណជេនឌ័រ

មិនមានច្បាប់ដែលដាក់ទោសព្រហ្មទណ្ឌលើការស្រឡាញ់ភេទដូចគ្នាឡើយ ហើយក៏មិនមានការរើសអើងជាផ្លូវការប្រឆាំងនឹងក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលដែលស្រឡាញ់ទាំងបុរស និងស្ត្រី និងអ្នកវះកាត់កែអវយវៈភេទ (LGBT) នោះទេ ទោះបីជានៅតែបន្តមានការរើសអើងពីសង្គមមួយចំនួន និងការនាំគ្នាស្អប់ក្តី ជាពិសេសនៅក្នុងតំបន់ជនបទ។ នៅខែឧសភា ក្រុមហ៊ុនក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរៀបចំកម្មវិធីសប្តាហ៍មោទនភាពប្រចាំឆ្នាំលើកទី ៦ របស់ក្រុម LGBT ដែលជាព្រឹត្តិការណ៍មានរយៈពេលមួយសប្តាហ៍ ។ ពិធីនោះមានការគាំទ្រជាទូទៅពីក្រុមអង្គការមិនមែនរដ្ឋាភិបាល ហើយរួមមានតំណាងរបស់ក្រុម LGBT មកពីប្រទេសជិតខាងផងដែរ។

មិនមានរបាយការណ៍អំពីការរើសអើងពីសំណាក់រដ្ឋាភិបាលផ្អែកលើលក្ខណៈនៃចំណង់ផ្លូវភេទនៅក្នុងការងារ ភាពគ្មានសញ្ជាតិ ឬលទ្ធភាពទទួលបានការអប់រំ ឬការថែទាំសុខភាពឡើយ។ ប៉ុន្តែ ការស្រឡាញ់ភេទដូចគ្នា ជាទូទៅ ទទួលរងការខ្មាស និងការសង្ស័យពីសំណាក់ប្រជាជនទូទៅ ហើយមានក្រុមគាំទ្រតិចតួចប៉ុណ្ណោះដែលគេអាចរាយការណ៍ប្រាប់ពីករណីរើសអើង ។ ការរើសអើងក្រៅផ្លូវការប្រឆាំងនឹងក្រុម LGBT

នៅតែមាន តែអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបាននិយាយថា ការរើសអើងមានការថយចុះ ដោយសារសហគមន៍របស់ក្រុម LGBT ធ្វើការបានល្អក្នុងការលើកកំពស់ការយល់ដឹង ។

គ្មានសេចក្តីរាយការណ៍ពីហឹង្សា ឬការបំពានទៅលើមនុស្សក្នុងក្រុម LGBT ទេ តែការមាក់ងាយ ឬការគំរាមកំហែងអាចជាកត្តាមួយក្នុងការរារាំងមិនអោយមានការរាយការណ៍ពីករណីបែបនេះ។

### ជំងឺអេដស៍ និងការមាក់ងាយ ក្នុងសង្គម

ការអង្កេតផ្នែកប្រជាសាស្ត្រ និងសុខភាព នៅឆ្នាំ ២០១០ បានកត់សំគាល់ថា ស្ត្រីចំនួន ២១% និងបុរសចំនួន ១៨% បាននិយាយពីការមានគំនិតរើសអើងទៅលើអ្នកដែលមានមេរោគអេដស៍។ អង្គការ UNAIDS បាននិយាយថា មានប្រជាជនកម្ពុជាចំនួន ៧៥ ០០០ នាក់ផ្ទុកមេរោគអេដស៍ នៅឆ្នាំ ២០១៣។

## ផ្នែកទី ៧៖សិទ្ធិកម្មករ និយោជិត

### ក. សេរីភាពចូលរួម និងសិទ្ធិចរចាអនុសញ្ញារួម (Freedom of Association and the Right to Collective Bargaining)

ច្បាប់ចែងពីការការពារសិទ្ធិរបស់អ្នកធ្វើការក្នុងវិស័យឯកជន ក្នុងការបង្កើតនិងចូលរួមក្នុងសហជីព តាមការជ្រើសរើសរបស់គេ ដោយគ្មានការអនុញ្ញាតជាមុន ពីសិទ្ធិក្នុងការធ្វើកូដកម្ម និងសិទ្ធិក្នុងការចរចាអនុសញ្ញារួម ។ ថ្វីបើសហជីពអាចចងសម្ព័ន្ធ ឬចូលរួមជាសមាជិកដោយសេរីក្តី តែច្បាប់មិនចែងច្បាស់ពីសិទ្ធិរបស់គេក្នុងការចងសម្ព័ន្ធ ឬចូលជាសមាជិកជាអន្តរជាតិទេ។

ច្បាប់តម្រូវឱ្យសហជីពដាក់បញ្ជូនលក្ខន្តិកៈ និងបញ្ជីឈ្មោះមន្ត្រីសហជីពទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT)។ ការិយាល័យទំនាក់ទំនងការងារទទួលបន្ទុកសម្របសម្រួលដំណើរការចុះបញ្ជីការសហជីព និងផ្តល់លិខិតបញ្ជាក់ “ភាពជាតំណាងបំផុត” សម្រាប់សហជីព ដែលផ្តល់សិទ្ធិឱ្យសហជីពដែលជាតំណាងកម្មករ-និយោជិតភាគច្រើននៅក្នុងសហគ្រាសណាមួយ ធ្វើជាតំណាងកម្មករ-និយោជិតទាំងអស់នៅក្នុងសហគ្រាសនោះ។

មន្ត្រីរាជការ រួមទាំង គ្រូបង្រៀន ចៅក្រម និងមន្ត្រីយោធា ព្រមទាំងអ្នកបម្រើការងារតាមផ្ទះ គ្មានសិទ្ធិបង្កើត ឬចូលរួមក្នុងសហជីពឡើយ។ បុគ្គលិកនៅក្នុងឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងផ្លូវទឹក មានសេរីភាពក្នុងការបង្កើតសហជីព ប៉ុន្តែមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍របបធានាផ្នែកសង្គម និងប្រាក់សោធននិវត្តន៍ឡើយ ហើយទទួលបានការលើកលែងពីការកំហិតម៉ោងការងារដែលមានចែងនៅក្នុងច្បាប់ការងារ។

ច្បាប់ចែងថា កូដកម្មអាចរៀបចំធ្វើបានលុះត្រាតែបំពេញតាមលក្ខខណ្ឌតម្រូវមួយចំនួនសិន ដែលរួមមានការបរាជ័យនៃវិធីសាស្រ្តដោះស្រាយវិវាទផ្សេងទៀត (ដូចជា ការចរចា ការផ្សះផ្សារ ឬមជ្ឈត្តកម្ម) ការបោះឆ្នោតសម្ងាត់ពីសមាជិកសហជីព និងការត្រូវជូនដំណឹងជាមុនរយៈពេល ៧ថ្ងៃ ដល់និយោជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ពុំមានច្បាប់ដែលហាមប្រាមមន្ត្រីរាជការ បុគ្គលិកនៅក្នុងវិស័យសាធារណៈ ឬបុគ្គលិកនៅក្នុងសេវាសំខាន់ៗមិនឱ្យធ្វើកូដកម្មឡើយ។ មានការការពារតាមផ្លូវច្បាប់ដែលការពារមេដឹកនាំសហជីពពីការបណ្តេញចេញពីការងារ។

បទប្បញ្ញត្តិស្តីពីសិទ្ធិចរចាអនុសញ្ញារួមនៃការងារតំរូវអោយសហជីពបង្ហាញថា ខ្លួនជាតំណាងកម្មករសំរាប់ការចរចាអនុសញ្ញារួម។ បទប្បញ្ញត្តិទាំងនេះផ្តល់សិទ្ធិឱ្យសហជីពដែលមានភាពជាតំណាងបំផុតធ្វើការចរចាអនុសញ្ញារួមហើយតម្រូវឱ្យនិយោជកត្រូវធ្វើការចរចា ប្រសិនបើសហជីពស្នើឱ្យមានកិច្ចព្រមព្រៀងអនុសញ្ញារួម។ បទប្បញ្ញត្តិទាំងនេះចងភ្ជាប់កាតព្វកិច្ចគូភាគីឱ្យឯកភាពនឹងដំណើរការចរចាដែលមានលំដាប់លំដោយត្រឹមត្រូវ និងផ្តល់សំណើ ក៏ដូចជាសំណើតបដែលសមស្រប និងសមហេតុផល ព្រមទាំងតម្រូវឱ្យនិយោជកផ្តល់ទីតាំង និងព័ត៌មានដែលទាក់ទងនឹងដំណើរការចរចាទាំងអស់ដល់សហជីពតាមការស្នើសុំរបស់សហជីព។ តែច្បាប់អនុញ្ញាតអោយភាគីទី៣ ធ្វើការជំទាស់នឹងការផ្តល់អោយសហជីពនូវភាពជាតំណាងបំផុត ដែលអាចជាមូលហេតុសំរាប់អោយរដ្ឋាភិបាលធ្វើការបដិសេធ។ អង្គការ ILO បានធ្វើការកត់សំគាល់ថា ការជំទាស់របស់ភាគីទី៣ ផ្ទុយនឹងសិទ្ធិការងារដែលត្រូវបានព្រមព្រៀងជាអន្តរជាតិ ទាក់ទងនឹងសេរីភាពក្នុងការចូលរួមបង្កើតក្រុមសមាគម និងការចរចាអនុសញ្ញារួម។

វិវាទការងារដែលដោះស្រាយមិនដាច់ស្រេច អាចបញ្ជូនទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាអង្គភាពរដ្ឋឯករាជ្យដែលបកស្រាយបទបញ្ញត្តិការងារនៅក្នុងករណីវិវាទសមូហភាព ដូចជា នៅពេលនិយោជិតជាច្រើនត្រូវបានបណ្តេញចេញពីការងារជាដើម។ គូភាគីអាចសម្រេចថា នឹងទទួលយកសេចក្តីសម្រេច ជាការភ្ជាប់ជាកាតព្វកិច្ចឬយ៉ាងណា។ ប្រសិនបើមិនមានភាគីណាមួយជំទាស់ទៅនឹងសេចក្តីសម្រេច

ទេនោះ នៅក្នុងរយៈពេល ៨ថ្ងៃ បន្ទាប់ការចេញសេចក្តីសម្រេច ភាគីត្រូវជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិ។ វិវាទនិមួយៗអាចយកមកដោះស្រាយនៅចំពោះមុខតុលាការ ទោះបីប្រព័ន្ធតុលាការមិនមានភាពអព្យាក្រិត និងតម្លាភាពក៏ដោយ (សូមមើលផ្នែក ១.ច)។

តាមសេចក្តីរាយការណ៍មក កម្មករជួបឧបសគ្គក្នុងការអនុវត្តសិទ្ធិរបស់គេក្នុងការចូលរួមក្នុងសហជីព ដោយសារនិយោជកខ្លះមិនព្រមចុះហត្ថលេខាលើសំបុត្រជូនដំណឹង ដែលទទួលស្គាល់សហជីពជាផ្លូវការ។ ក្រៅពីនេះទៀត កម្មករនៅក្នុងវិស័យកាត់ដេរនៅកម្ពុជាត្រូវបានជួលដូចជាអ្នកម៉ៅការបន្ត ដែលជាការធ្វើអោយការចូល ឬបង្កើតសហជីពមានការពិបាក។ ការពង្រឹងការអនុវត្តសិទ្ធិចូលរួមសមាគម និងសេរីភាពរួចផុតពីការរើសអើងប្រឆាំងនឹងសមាជីពគ្មានលក្ខណៈស៊ីសង្វាក់គ្នាទេ។ ទង្វើរើសអើង គំរាមកំហែង និងទង្វើសងសឹកប្រឆាំងនឹងសហជីពពីសំណាក់និយោជកស្ទើរតែគ្រប់ពេល មិនទទួលការដាក់ទណ្ឌកម្មទេ។ ពេលខ្លះ កិច្ចការរបស់រដ្ឋាភិបាលក្នុងការពង្រឹងការអនុវត្តសិទ្ធិទាំងនេះត្រូវបន្ទុចបង្អាក់ដោយសារទំនាក់ទំនងជិតស្និទ្ធនៅក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និយោជក និងមេដឹកនាំសហជីព។ ទំនាក់ទំនងទាំងនេះបង្អាក់មិនអោយមេដឹកនាំសហជីពរាយការណ៍ពីករណីរើសអើង ហើយរាំងស្ទះដល់ដំណើរការដោយឯករាជ្យរបស់សហជីព។ មេដឹកនាំសហជីពដែលមានទំនោរទៅរដ្ឋាភិបាល មិនបានធ្វើការដោយឯករាជ្យទេ ហើយពេលខ្លះមិនបានរាយការណ៍ពីករណីរើសអើងរបស់សហជីពទៅរដ្ឋាភិបាលទេ។ រដ្ឋាភិបាលក៏មិនផ្តល់ធនធានគ្រប់គ្រាន់សំរាប់ការពង្រឹងផ្នែកអនុវត្តច្បាប់ទេ ដូចជាការផ្តល់ការបណ្តុះបណ្តាល និងធនធានដើម្បីធានាអោយក្រុមអធិការកិច្ចការងារធ្វើការបានល្អជាធម្មតា។ នៅក្នុងអំឡុងពេល ៦ ខែដំបូងនៃឆ្នាំរបាយការណ៍ សហជីពឯករាជ្យយ៉ាងហោចណាស់ ៥ បាននិយាយថា គេមិនអាចចុះឈ្មោះតំណាងសហជីពដែលទើបបង្កើតថ្មី នៅតាមរោងចក្រចំនួនប្រហែល ៣០ ពីព្រោះក្រសួងសង្គមកិច្ចទាមទារព័ត៌មានបន្ថែម ដូចជាប្រវត្តិទាក់ទងនឹងតំណាងសហជីពដែលចង់ចុះឈ្មោះ។ ក្រសួងបានបដិសេធការចោទប្រកាន់ពីលើការមិនព្រមចុះបញ្ជីសហជីពថ្មីៗ ហើយនិយាយថា និតិវិធីរបស់ខ្លួនស្របតាមច្បាប់។

ការពង្រឹងការអនុវត្តសិទ្ធិចរចាអនុសញ្ញារួមរបស់រដ្ឋាភិបាលមានលក្ខណៈមិនស៊ីសង្វាក់ទេ។ ដោយគិតមកដល់ខែមិថុនា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានព្រមានជាផ្លូវការដល់ក្រុមហ៊ុនចំនួន ១៧៨ ពីបទរំលោភច្បាប់។ ទោះបីជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជារឿយៗ បានសម្រេចដោយឈរលើផលប្រយោជន៍របស់និយោជិតក៏ដោយ ក៏ក្រសួងកម្របានប្រើប្រាស់សិទ្ធិអំណាចស្របច្បាប់របស់ខ្លួនដើម្បីដាក់ពិន័យដល់និយោជកដែលមិនអនុវត្តបទបញ្ជារបស់ខ្លួនណាស់។ នៅក្នុងអំឡុងពេល ៦ ខែដំបូងនៃឆ្នាំ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលករណីជំលោះចំនួន ៦៧ ដែលមិនទាក់ទង

នឹងកូដកម្ម ហើយផ្នែកដោះស្រាយជំលោះការងាររបស់ក្រសួងបានដោះស្រាយដោយជោគជ័យនូវករណីចំនួន ១៤។ នៅក្នុងពេលទន្ទឹមនឹងនោះ មានបណ្តឹងចំនួន ៦៧ ទាក់ទងនឹងកូដកម្មត្រូវបានប្តឹងទៅក្រសួងសង្គមកិច្ច ដោយក្នុងនោះ បណ្តឹងចំនួន ២១ ត្រូវបានដោះស្រាយចេញ។ ផ្នែកដោះស្រាយជំលោះការងាររបស់ក្រសួង បានផ្ញើករណីដែលមិនត្រូវបានដោះស្រាយចំនួន ៩៧ ទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ សហជីពមួយចំនួនបាន ជំរុញឱ្យរដ្ឋាភិបាលពង្រីកតួនាទីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយអោយរួមបញ្ចូលករណីវិវាទផល ប្រយោជន៍បុគ្គល និងវិវាទផលប្រយោជន៍សមូហភាព ព្រមទាំងធ្វើឱ្យមានការភ្ជាប់កាតព្វកិច្ចចំពោះសេចក្តី សម្រេចរបស់ក្រុមប្រឹក្សាផងដែរ។ ពីខែមករាដល់ខែមិថុនា ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿង ចំនួន ១៧៤ ដែលជាចំនួនមានការកើនចំនួន ២៤%ពីរយៈពេលដដែលក្នុងឆ្នាំមុននោះ។ ក្រុមប្រឹក្សាបានរាយ ការណ៍ថា ក្នុងចំណោមករណីទាំង ១៧៤ ខ្លួនបានដោះស្រាយករណីចំនួន ៤៨ ហើយ ដោយធ្វើបានធ្វើជា អាជ្ញាកណ្តាលដោះស្រាយ ៦៥ ករណីត្រូវបានដោះស្រាយដោយភាគី មុនពេលសំរេចដោយក្រុមប្រឹក្សា ហើយមាន ២០ ករណីត្រូវបានបិទ ដោយសារខ្វះការចូលរួម ឬការធ្វើសហប្រតិបត្តិការដោយភាគីនានា ហើយករណីសល់ពីនេះ នៅកំពុងដោះស្រាយ។

សហជីពភាគច្រើនមានសម្ព័ន្ធភាពជាមួយគណបក្សកាន់អំណាច ខ្លះមានសម្ព័ន្ធភាពជាមួយគណបក្ស ប្រឆាំង ហើយខ្លះទៀតជាសហជីពឯករាជ្យ។

ការរៀបចំបង្កើតសហជីព ឬសមាគមនៅក្នុងចំណោមបុគ្គលិកវិស័យសាធារណៈនៅតែប្រឈមមុខនឹង ឧបសគ្គធំៗ។ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាបានចុះបញ្ជីការជា “សមាគម” ដោយសារការហាមឃាត់ ការបង្កើតសហជីពក្នុងវិស័យសាធារណៈ ហើយ រដ្ឋាភិបាលបានបដិសេធសំណើសុំការធ្វើការដង្ហែរក្បួន និងធ្វើការតវ៉ា ទោះបីជាខ្លួនបានរាយការណ៍ថា មិនមានការជ្រៀតជ្រែកដោយផ្ទាល់ណាមួយពីរដ្ឋាភិបាល ក្នុងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួនក៏ដោយ។ សមាជិកមួយចំនួនភ័យខ្លាចថា សម្ព័ន្ធភាពរបស់ខ្លួនជាមួយនឹង សមាគមអាចជាឧបសគ្គដល់អាជីពទៅមុខរបស់គេ។ សមាគមវិស័យសាធារណៈមួយផ្សេងទៀតគឺ សមាគមមន្រ្តីរាជការឯករាជ្យកម្ពុជា បានលើកឡើងថា ការភ័យខ្លាចការបៀតបៀន ការរើសអើង ឬបញ្ចុះ តំណែងជាកត្តាដែលរារាំងគេមិនឱ្យចូលរួមក្នុងសមាគម។

នៅខែធ្នូ ឆ្នាំ ២០១៣ កម្មករកាត់ដេររាប់ពាន់នាក់បានដើរចេញពីការងារ ដើម្បីតវ៉ានឹងគំរោងរបស់រដ្ឋា ភិបាលក្នុងការដំឡើងប្រាក់ខែអប្បបរិមាររបស់គេដល់ ៣៨៥ ០០០ រៀល (៩៥ ដុល្លា) ដែលជាចំនួនតិចជាង ច្រើនទៅនឹងចំនួនទាមទាររបស់សហជីពដែលចង់បាន ៦៥០ ០០០ រៀល (១៦០ ដុល្លា) ក្នុងមួយខែ។ ប៉ុន្មាន

ថ្ងៃក្រោយមក ចំនួនអ្នកតវ៉ាមានកាន់តែច្រើនឡើង។ នៅថ្ងៃទី ២ ខែមករា កំលាំងសន្តិសុខបានប៉ះទង្គិចដោយហឹង្សាជាមួយអ្នកតវ៉ាចំនួនជាង ៥០០ នាក់ ដែលតាមសេចក្តីរាយការណ៍មកថា បានគប់ដុំថ្ម នៅមុខរោងចក្រកាត់ដេរ Yakjin ក្នុងរាជធានីភ្នំពេញ។ នៅថ្ងៃទី ៣ ខែមករា កងរាជអាវុធហត្ថបានប៉ះទង្គិចជាមួយក្រុមអ្នកតវ៉ាផ្សេងៗ នៅក្រៅរោងចក្រកាណាឌីយ៉ា ជិតរាជធានីភ្នំពេញ។ អ្នកតវ៉ាត្រូវបានរាយការណ៍មកថា បានដុតកង់ឡាន ហើយគប់ដុំថ្មដាក់កំលាំងសន្តិសុខ ក្រោយពីអាជ្ញាធរប៉ុនប៉ងបំបែកការតវ៉ា។ នគរបាលបានឆ្លើយតបដោយបាញ់ឧស្ម័នបង្ហៀរទឹកភ្នែក ហើយទីបំផុត បានបាញ់គ្រាប់ពិត ដែលបណ្តាលអោយមានស្លាប់ ៤ នាក់ និងរបួសចំនួនជាង ៣៥ នាក់ (សូមមើលផ្នែក ១.ក)។

នគរបាលបានចាប់ខ្លួន និងឃុំខ្លួនមនុស្សចំនួន ២៣ នាក់ នៅកន្លែងតវ៉ាថ្ងៃទី ២ និង ៣ មករា។ អ្នកជាប់ឃុំទាំងនោះត្រូវបានដោះលែងវិញ នៅខែឧសភា បន្ទាប់ពីតុលាការក្រុងភ្នំពេញបានដាក់ទោសនិងដាក់ទោសពួកគេពីបទញុះញង់អោយមានហឹង្សា តែបានព្យួរទោសរបស់គេ។ អ្នកសង្កេតការណ៍បានរិះគន់យ៉ាងខ្លាំងលើការឃុំខ្លួនអ្នកទាំងនោះ និងដំណើរការក្តីក្នុងតុលាការប្រឆាំងទៅលើពួកគេ ដោយនិយាយថា អ្នកដែលត្រូវបានឃុំខ្លួនទាំងនោះបានអនុវត្តសិទ្ធិរបស់គេ ក្នុងការតវ៉ា ហើយត្រូវបានឃុំខ្លួនដោយគ្មានការកាត់ក្តីត្រឹមត្រូវ។

រដ្ឋាភិបាលបានហាមប្រាមលើការប្រមូលផ្តុំគ្នាជាសាធារណៈ បន្ទាប់ពីមានហឹង្សាកើតឡើងនៅថ្ងៃទី ២ និងទី ៣ ខែមករា។ រដ្ឋាភិបាលបានអនុញ្ញាតឱ្យមានកូដកម្មភាគច្រើននៅក្នុងរោងចក្រ ទោះបីជាថា អ្នកធ្វើកូដកម្មកម្រផ្តល់ដំណឹងជាមុនតាមការកំណត់ដោយច្បាប់ក្តី។ រដ្ឋាភិបាលមិនផ្តល់ការអនុញ្ញាតអោយធ្វើការដើរហែរ នៅក្រៅរោងចក្រទេ។ លើសពីនេះទៀត នគរបាលចូលអន្តរាគម នៅពេលកម្មកររោងចក្របិទផ្លូវធំៗ ក្នុងរាជធានីភ្នំពេញ។

នៅខែមិថុនា ឆ្នាំ ២០១៣ តុលាការខេត្តស្វាយរៀងបានកាត់ទោសកំបាំងមុខអោយអតីតអភិបាលក្រុងបាវិត ឈ្មោះ ឈូក បណ្ឌិតជាប់ពន្ធនាគារចំនួន ១៨ ខែ ពីបទចោទថា បានបាញ់ហ្វូងកម្មករកាត់ដេរតវ៉ាចំនួនប្រមាណ ៥០០០ នាក់ ហើយធ្វើអោយរបួសស្រ្តី ៣ នាក់។ មកដល់ខែតុលា ឆ្នាំ ២០១៣ សាលាឧទ្ធរណ៍បានដំកល់សាលដីការនោះ តែគិតត្រឹមខែតុលា ឈ្មោះ ឈូក បណ្ឌិតនៅគេចខ្លួននៅឡើយ។

មានរបាយការណ៍គួរអោយជឿទុកចិត្តថា មានការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសហជីពពីសំណាក់និយោជក រួមទាំងការបណ្តេញមេដឹកនាំសហជីពក្នុងរោងចក្រកាត់ដេរ និងសហគ្រាសផ្សេងទៀតចេញពីការងារផងដែរ។ នៅក្នុងរោងចក្រមួយចំនួន ថៅកែទំនងជាបានបង្កើត ឬគាំទ្រសហជីពដែលគាំទ្រថៅកែ ឬ

បន្ថយឥទ្ធិពលមេដឹកនាំសហជីព ដោយបង្ករបញ្ហាដល់ការងាររបស់ពួកគេ។ បន្ទាប់ពីមានការតវ៉ាដោយហឹង្សារបស់កម្មករ នៅខែតុលា ឆ្នាំ ២០១៣ សមាគមរោងចក្រកាត់ដេរកម្ពុជា (GMAC) បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញប្រឆាំងនឹងសហព័ន្ធសហជីពឯករាជ្យចំនួន ៦ ដោយចោទថា សហព័ន្ធសហជីពទាំងនោះបានញុះញុងអោយកម្មករធ្វើការតវ៉ាដោយហឹង្សា ដែលនាំអោយខូចដល់ទ្រព្យសម្បត្តិ និងផលិតកម្មរបស់រោងចក្រ។ គិតមកដល់ខែមិថុនា សហជីពឯករាជ្យចំនួន ៥ បាននិយាយថា មានតំណាងសហជីពចំនួន ៣៩ រូបនៅតាមរោងចក្រចំនួន ១១ ត្រូវបានគេបណ្តេញចេញ ដោយសារពួកគេចូលសហជីព។

ទោះបីជាបទប្បញ្ញត្តិច្បាប់ការពារកូដករពីការសងសឹកក៏ដោយ ក៏មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា កម្មករ-និយោជិតត្រូវបានបណ្តេញចេញពីការងារដោយឈរលើមូលដ្ឋានមិនពិត បន្ទាប់ពីពួកគេបានរៀបចំ ឬចូលរួមនៅក្នុងកូដកម្ម។ ទោះបីជាកូដកម្មភាគច្រើនមិនស្របច្បាប់ក៏ដោយ តែការចូលរួមនៅក្នុងកូដកម្មមិនស្របច្បាប់មិនមែនជាហេតុផលដែលអាចទទួលយកបានតាមផ្លូវច្បាប់ សំរាប់បណ្តេញកម្មករ-និយោជិតចេញពីការងារឡើយ។ នៅក្នុងករណីខ្លះ និយោជកបានដាក់សម្ពាធលើកូដករឱ្យទទួលយកសំណង ហើយឈប់ពីការងាររបស់ខ្លួន។

មានដំណោះស្រាយសម្រាប់បញ្ហានៃការបណ្តេញចេញពីការងារបែបនេះ តែគ្មានដំណោះស្រាយណាមួយដែលត្រូវបានចាត់ទុកថាមានប្រសិទ្ធភាពនោះទេ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចចេញបទបញ្ជាឱ្យប្រគល់ការងារទៅឱ្យកម្មករ-និយោជិតវិញបាន ប៉ុន្តែជារឿយៗ បទបញ្ជាទាំងនេះបានបង្កឱ្យមានការដាក់សម្ពាធពីថៅកែឱ្យកម្មករលាឈប់ពីការងារ ជាថ្នូរទៅនឹងការទូទាត់លុយទៅវិញ។ ពេលខ្លះថៅកែមិនបានគោរពសាលក្រមរបស់តុលាការអោយទទួលយកកម្មករអោយចូលធ្វើការវិញទេ ។

នៅឆ្នាំ ២០១២ សមាគមរោងចក្រកាត់ដេរកម្ពុជា និងសហព័ន្ធសហជីពចំនួន ៨ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា (MOU) មួយ ដែលអ្នកសង្កេតការជាច្រើនជឿថា នឹងនាំដល់ការចរចាអនុសញ្ញារួមបានច្រើន ហើយបន្ថយការធ្វើកូដកម្ម។ MOU នេះកំណត់អោយរោងចក្រ និងកម្មករ និយោជិតទទួលយកការសំរេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហត្ថលេខីលើ MOU បានធ្វើការប្រជុំប្រចាំត្រីមាស នៅខែកុម្ភៈ និងខែកក្កដា ដើម្បីពិភាក្សាពីការអនុវត្តតាម MOU និងការពង្រឹងការអនុវត្តការសំរេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

### ខ. ការហាមឃាត់មិនអោយមានការងារដោយបង្ខំ ឬការងារបែបកាតព្វកិច្ច

ច្បាប់ហាមប្រាមមិនអោយមានការងារដោយបង្ខំ ឬជាកាតព្វកិច្ចទេ ប៉ុន្តែ មានការរាយការណ៍ថា ការធ្វើដូច្នេះមានឡើងនៅក្នុងការងារតាមផ្ទះ និងនៅក្នុងវិស័យក្រៅផ្លូវការ។ កុមារនៅក្នុងគ្រួសារក្រីក្រនៅតែប្រឈមនឹងហានិភ័យ ដោយសារពេលខ្លះ គ្រួសារអ្នកមានបានយកលេសមនុស្សធម៌ដើម្បីជួលគេឱ្យធ្វើជាអ្នកបម្រើតាមផ្ទះ ប៉ុន្តែបែរជារំលោភបំពាន និងកេងប្រវ័ញ្ចពួកគេ។ មានការនិយាយផងដែរពីការបង្ខំអោយធ្វើពលកម្មក្នុងផ្នែកនេសាទ កសិកម្ម និងផ្នែកសំណង់។ មន្ត្រីរដ្ឋាភិបាលបានរាយការណ៍ថា ការពិនិត្យស្ថានភាពការងារ និងប្រាក់បៀវត្សរ៍របស់អ្នកបម្រើតាមផ្ទះ អ្នកធ្វើការក្នុងផ្នែកនេសាទ កសិកម្ម និងផ្នែកសំណង់ នៅតែមានការលំបាកដោយសារតែលក្ខណៈក្រៅផ្លូវការនៃការងាររបស់គេ។

សូមចូលមើល*របាយការណ៍ស្តីពីការជួញដូរមនុស្ស*របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក តាមគេហទំព័រ www.state.gov/j/tip/rls/tiprpt/ ។

### គ. ការហាមឃាត់ចំពោះពលកម្មកុមារ និងអាយុធ្វើការងារអប្បបរិមា

ច្បាប់កំណត់ថា អាយុធ្វើការងារអប្បបរិមាគឺ ១៥ ឆ្នាំ ហើយសម្រាប់ការងារដែលមានគ្រោះថ្នាក់ អាយុអប្បបរិមានេះគឺ ១៨ ឆ្នាំ។ ច្បាប់អនុញ្ញាតឱ្យកុមារអាយុចន្លោះពី ១២ ទៅ ១៥ឆ្នាំ ចូលរួមក្នុង “ការងារស្រាល” ដែលជាការងារមិនមានគ្រោះថ្នាក់ដល់សុខភាពរបស់កុមារទាំងនោះ ក៏ដូចជាមិនប៉ះពាល់ដល់ការសិក្សា។ ច្បាប់កំណត់ថា ម៉ោងការងាររបស់កុមារអាយុ ១២ ទៅ ១៥ឆ្នាំ មិនអាចលើសពី ៤ ម៉ោងក្នុងមួយថ្ងៃឡើយ សម្រាប់ថ្ងៃសិក្សា និង ៧ ម៉ោងក្នុងមួយថ្ងៃ សម្រាប់ថ្ងៃឈប់សម្រាក ហើយហាមឃាត់ការធ្វើការនៅចន្លោះពីម៉ោង ៨:០០ យប់ ដល់ម៉ោង ៦:០០ព្រឹក។ រដ្ឋាភិបាលក៏ហាមឃាត់ការទទួលកុមារឱ្យបម្រើការងារនៅក្នុងវិស័យ ដែលមានហានិភ័យចម្បងដល់សុវត្ថិភាព ឬហានិភ័យសុខភាពចំពោះអនីតិជន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានការទទួលខុសត្រូវក្នុងការធ្វើអធិការកិច្ចលើពលកម្មកុមារ ទាំងក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ និងក្រៅផ្លូវការ ប៉ុន្តែ អធិការការងាររបស់ក្រសួងនេះមិនបានធ្វើអធិការកិច្ចក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ ឬពង្រឹងការអនុវត្តច្បាប់នៅក្នុងឧស្សាហកម្មខុសច្បាប់ទេ ដូចជានៅតាមរោងចក្រកាត់ដេរដែលមិនចុះបញ្ជីការ និងបើកដំណើរការដោយមិនមានអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្មទេ។ នៅក្នុងវិស័យផ្លូវការ អធិការការងារបានធ្វើការពិនិត្យជាប្រចាំចំពោះឧស្សាហកម្មមួយចំនួន ដូចជាវិស័យកាត់ដេរ (ដែលមានបញ្ហាពលកម្មកុមារតិចតួចប៉ុណ្ណោះ) ប៉ុន្តែ នៅក្នុងឧស្សាហកម្មមួយចំនួនទៀតដែលអាចមានពលកម្មកុមារខ្ពស់បំផុត ការធ្វើអធិការកិច្ចការងារកើតឡើងតែក្នុងករណីដែលមានពាក្យបណ្តឹងប៉ុណ្ណោះ។ មានអធិការការងារចំនួន ១២ នាក់នៅក្នុង រាជធានី

ភ្នំពេញ និង ២៧នាក់ នៅថ្នាក់ក្រុង និងខេត្តដែលទទួលបន្ទុកបញ្ហាពលកម្មកុមារ។ តែដោយសារគេមានការងាររដ្ឋបាលត្រូវធ្វើផងដែរ ដូច្នេះ គេមិនមែនផ្តោតការយកចិត្តទុកដាក់តែទៅលើកង្វល់ស្តីពីពលកម្មកុមារតែមួយមុខនោះទេ។ ចំនួនអធិការការងារទាំងនេះមិនគ្រប់គ្រាន់ក្នុងការពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធឡើយ។ ច្បាប់ការងារចែងអំពីការដាក់ពិន័យចំនួនពី ៣១ ទៅ ៦០ ដង នៃប្រាក់ឈ្នួលប្រចាំខែសំរាប់ចុងចោទដែលត្រូវបានតុលាការរកឃើញថា បានបទរំលោភលើបទបញ្ញត្តិស្តីពីពលកម្មកុមារ។

ពលកម្មកុមារមានច្រើនក្នុងផ្នែកកសិកម្ម សិប្បកម្មផលិតឥដ្ឋ ការលីសែង ការដ្ឋានផលិតអំបិល សិប្បកម្មកែច្នៃបង្គារ វិស័យនេសាទ ការងារតាមផ្ទះ និងផលិតកម្មកៅស៊ូ វាយនភណ្ឌ ការកាប់ឈើ សត្វឃាត និងការផលិតស្រា ស្រាបៀ។ កុមារក៏មានធ្វើជាអ្នកសុំទាន អ្នកដើរលក់តាមផ្លូវ អ្នកខាត់ស្បែកជើង និងអ្នកដើររើសរបស់អេតចាយផងដែរ។ពលកម្មកុមារក៏ត្រូវបានគេរាយការណ៍ថា មាននៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ក៏ដូចជាវិស័យបដិសណ្ឋារកិច្ចផងដែរ ។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន សំរាប់ពីខែឧសភា ឆ្នាំ ២០១៣ ដល់ខែមេសា ឆ្នាំ ២០១៤ កម្មវិធីដែលមានឈ្មោះថាកម្មវិធីរោងកច្រល្អនៅកម្ពុជា ដែលជាកម្មវិធីតាមដានដោយឯករាជ្យមួយទៅលើវិស័យកាត់ដេរ បានរកឃើញថា នៅតាមរោងចក្រចំនួន ១៤ ក្នុងចំណោមរោងចក្រ ចំនួន ៣១៧ ដែលមាននិយាយនៅក្នុងរបាយការណ៍នេះ បានប្រើកម្មករដែលមានអាយុក្រោម ១៥ ឆ្នាំ នៅពេលគេចូលធ្វើការ ។

សូមចូលមើល *របកគំហើញស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ* របស់ក្រសួងការងារសហរដ្ឋអាមេរិក តាមគេហទំព័រ www.dol.gov/ilab/reports/child-labor/findings/ ។

**ឃ. ការរើសអើងទាក់ទងនឹងការងារ**

ច្បាប់ហាមប្រាមការរើសអើងដោយសារពូជសាសន៍ ពណ៌សម្បុរ ជំនឿ សាសនា ភេទ ពិការភាព មតិនយោបាយ កំណើត ប្រវត្តិដើម ឬសមាជិកភាពក្នុងសហជីព។ រដ្ឋធម្មនុញ្ញចែងថា ពលរដ្ឋខ្មែរទាំង ២ ភេទត្រូវទទួលប្រាក់បៀវត្សស្មើគ្នា ចំពោះការងារស្មើគ្នា។ ជាទូទៅ រដ្ឋាភិបាលគ្មានសមត្ថភាពក្នុងការពង្រឹងលើការអនុវត្តច្បាប់ទាំងនេះទេ។ កម្មវិធីរោងចក្រល្អនៅកម្ពុជាបាននិយាយថា នៅក្នុងវិស័យកាត់ដេរ ម្ចាស់រោងចក្ររើសអើងយ៉ាងខ្លាំងលើបុរស នៅក្នុងការជ្រើសរើសអោយចូលធ្វើការ និងការផ្តល់ប្រាក់ឧបត្ថម្ភ។ កម្មវិធីនេះបានប៉ាន់ប្រមាណថា មានតែពី ១០ ទៅ ១៥ ភាគរយនៃកម្មកររោងចក្រកាត់ដេរទេ ដែលជាបុរស។ អង្គការ ILO បានកត់សំគាល់ដោយកង្វល់ នូវរបាយការណ៍នៃការរើសអើងរបស់ថៅកែ តាមរយៈការជ្រៀតជ្រែក និងការបណ្តេញចេញនូវពីការងារនូវសមាជិកនៃសហជីពឯករាជ្យ ព្រមទាំងតាមរយៈការបង្កើតសហ

ជីពដែលគាំទ្រដោយថៅកែ។ គណកម្មាធិការនៃអ្នកជំនាញរបស់អង្គការ ILO បានអំពាវនាវអោយមានការកែប្រែច្បាប់ ដើម្បីផ្តល់ការការពារគ្រប់គ្រាន់ប្រឆាំងនឹងការរើសអើងទៅលើសហជីព ហើយធ្វើការដាក់ទោសអោយបានគ្រប់គ្រាន់ដើម្បីអោយរាង (សូមមើលនៅត្រង់ផ្នែកលេខ ៦)។

## ឃ. លក្ខខ័ណ្ឌការងារដែលអាចទទួលយកបាន

ច្បាប់តម្រូវឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំណត់ប្រាក់ឈ្នួលអប្បបរិមាក្នុងវិស័យកាត់ដេរ ដោយផ្អែកលើអនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាការងារ ដែលជាក្រុមមានបីភាគី គឺតំណាងរដ្ឋាភិបាលកម្ពុជា សហជីព និងស្ថាប័ននិយោជក។ នៅខែធ្នូ ឆ្នាំ ២០១៣ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាសប្រាក់ខែអប្បរិមាថ្មីចំនួន ៣៦៥ ០០០ រៀល (៩០ ដុល្លាអាមេរិក) ក្នុងមួយខែ ដែលជាការកើនឡើងចំនួន ៦០ ០០០ រៀល (១៥ ដុល្លាអាមេរិក) ។ ក្រោយពីការប្រកាសនេះ មានការតវ៉ាយ៉ាងច្រើនពីព្រោះចំនួនឡើងនេះទាបជាងចំនួន ៦៥០ ០០០ រៀល (១៦០ ដុល្លាអាមេរិក) ក្នុងមួយខែ ដែលសហជីពបានទាមទារ។ ក្រោយពីការតវ៉ាអស់មួយសប្តាហ៍ ក្រសួងការងារបានប្រកាសការដំឡើងបន្ថែមចំនួន ២០ ០០០ រៀល (៥ ដុល្លា) ទៀត លើចំនួន ៤០៥ ០០០ រៀល (១០០ ដុល្លាអាមេរិក) ក្នុងមួយខែ តែការតវ៉ានៅតែបន្តហើយមានហឹង្សា នៅថ្ងៃទី ២ និងទី ៣ ខែមករា។ ច្បាប់មិនកំណត់ប្រាក់ខែអប្បបរិមាសំរាប់វិស័យណាមួយផ្សេងទៀតទេ។ ធនាគារពិភពលោកកំណត់ប្រាក់ចំណូលត្រឹម ៥.០០០រៀល (១,២៥ដុល្លារអាមេរិក) ក្នុងមួយថ្ងៃជាកម្រិតខ្សែបន្ទាត់ភាពក្រីក្រ។ បន្ទាប់ពីគណកម្មាធិការប្រឹក្សាការងារបានធ្វើសេចក្តីប្រកាសភ្លាមលោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានបញ្ជាអោយក្រសួងការងារដំឡើងបៀវត្សអប្បបរិមាចំនួន ២០ ០០០ រៀល គឺអោយឡើងដល់ ៥១៩ ០០០ រៀល (១២៨ ដុល្លាអាមេរិក) ។ ក្រសួងបានប្រកាសថា ប្រាក់ខែអប្បបរិមាថ្មីចំនួន ១២៨ ដុល្លាអាមេរិកនឹងចូលជាធរមាន នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៥។

ច្បាប់ចែងម៉ោងធ្វើការជាបទដ្ឋានតាមច្បាប់ចំនួន ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ហើយមិនលើសពី ៨ ម៉ោងក្នុងមួយថ្ងៃឡើយ។ ច្បាប់កំណត់អត្រាបៀវត្សការងារនៅពេលយប់ចំនួន ១៣០% នៃបៀវត្សការងារនៅពេលថ្ងៃ និង១៥០% នៃបៀវត្សការងារពេលថ្ងៃសំរាប់ម៉ោងបន្ថែម ហើយអត្រានេះឡើងដល់ ២០០% បើការងារថែមម៉ោងនោះត្រូវបានធ្វើនៅពេលយប់ នៅថ្ងៃអាទិត្យ ឬចំថ្ងៃបុណ្យ។ កម្មករនិយោជិតត្រូវបានអនុញ្ញាតអោយធ្វើការថែមម៉ោងចំនួន ២ ម៉ោង ក្នុងមួយថ្ងៃ។ ច្បាប់ដែលហាមការធ្វើការលើសម៉ោងច្រើនពេក ចែងថាការងារថែមម៉ោងទាំងអស់ត្រូវតែធ្វើតាមការស្ម័គ្រចិត្ត និងមានចែងពីថ្ងៃឈប់សំរាកប្រចាំឆ្នាំដោយមានទទួលប្រាក់បៀវត្ស។

ច្បាប់ចែងថា កន្លែងធ្វើការគួរមានស្តង់ដារសុខភាព និងសុវត្ថិភាពគ្រប់គ្រាន់សំរាប់សុខមាលភាពរបស់កម្មករ-និយោជិត។ ច្បាប់មានចែងអំពីការពិន័យដែរ ប៉ុន្តែ មិនមានបទប្បញ្ញត្តិជាក់លាក់ដើម្បីការពារកម្មករ-និយោជិត ដែលតវ៉ាអំពីស្ថានភាពគ្មានសុវត្ថិភាព ឬប៉ះពាល់ដល់សុខភាពឡើយ។

រដ្ឋាភិបាលមិនបានពង្រឹងការអនុវត្តស្តង់ដារពាក់ព័ន្ធនឹងប្រាក់ឈ្នួលលើម៉ោងការងារ និងសំណងការងារថែមម៉ោង ឱ្យមានប្រសិទ្ធភាពឡើយ។ កម្មករ-និយោជិតបាននិយាយថា ជារឿយៗ ការងារថែមម៉ោងមានចំនួនលើសលុបពេក ហើយពេលខ្លះជាការតម្រូវឱ្យធ្វើតែម្តង។ នៅក្រៅពីឧស្សាហកម្មកាត់ដេរ បទប្បញ្ញត្តិស្តីពីម៉ោងការងារ កម្រត្រូវបានអនុវត្តណាស់។ ការងារថែមម៉ោងមិនទៅតាមការស្ម័គ្រចិត្តនៅតែជាបញ្ហាមួយ គ្រាន់តែមានការថយចុះនៅអំឡុងឆ្នាំនៃរបាយការណ៍នេះ។ និយោជកច្រើនតែបានបង្ខិតបង្ខំឱ្យនិយោជិតធ្វើការងារ។ ជារឿយៗ បុគ្គលិកកម្មករប្រឈមមុខនឹងការពិន័យ ការបណ្តេញចេញពីការងារ ឬការបាត់បង់ប្រាក់ឧបត្ថម្ភ ប្រសិនបើពួកគេមិនព្រមធ្វើការងារថែមម៉ោង។

រដ្ឋាភិបាលបានពង្រឹងការអនុវត្តស្តង់ដារដែលត្រូវបានកំណត់ដោយមិនបានខ្ជាប់ខ្ជួនទេ ម្យ៉ាងដោយសារខ្វះបុគ្គលិកដែលមានជំនាញ និងខ្វះឧបករណ៍។ នាយកដ្ឋានអធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគឺជាទីភ្នាក់ងារពង្រឹងការអនុវត្តដ៏ចម្បងមួយ ហើយនៅអំឡុងឆ្នាំនេះ ទីភ្នាក់ងារបានចេញការព្រមានចំនួន ១៧៨ ដល់ក្រុមហ៊ុន ទាក់ទងនឹងការរំលោភលើច្បាប់ការងារ ក្នុងរយៈពេល ៦ ខែដំបូង។ ទោះបីជាក្រសួងការងារមានអ្នកធ្វើអធិការកិច្ចក្តី តែកង្វះថវិកា អំពើពុករលួយដែលមានរាលដាល និងការដាក់ពិន័យមិនគ្រប់គ្រាន់បានបន្ទុចបង្អាក់ដល់ប្រសិទ្ធភាពការងារនេះ។ ដោយលើកឡើងពីកង្វះធនធានមនុស្ស និងថវិកា ក្រសួងការងារមិនបានធ្វើអធិការកិច្ចតាមរោងចក្របានគ្រប់គ្រាន់ និងទៀងទាត់ទេ។

របួស និងបញ្ហាសុខភាពដែលពាក់ព័ន្ធនឹងការបំពេញការងារ កើតមានជាទូទៅ។ រោងចក្រកាត់ដេរធំៗភាគច្រើនដែលផលិតសម្រាប់ទីផ្សារនៅក្នុងប្រទេសអភិវឌ្ឍន៍បានបំពេញតាមស្តង់ដារសុខភាព និងសុវត្ថិភាពបានខ្ពស់គួរសម ដោយសារតែមានលក្ខខណ្ឌកិច្ចសន្យារបស់ខ្លួនជាមួយអ្នកទិញ។ ចំណែកលក្ខខណ្ឌការងារនៅក្នុងរោងចក្រខ្នាតតូច និងសិប្បកម្មវិញ មានលក្ខខណ្ឌមិនល្អទេ ហើយជារឿយៗ មិនបានបំពេញស្តង់ដារអន្តរជាតិឡើយ។ មូលនិធិជាតិផ្នែកសន្តិសុខសង្គមបានរាយការណ៍ថា នៅក្នុងរយៈពេល ៦ ខែដំបូង មាន ៦៥៩៤ ករណីរបួសពេលកំពុងបំពេញការងារ និង មានស្លាប់ចំនួន ៥១ នាក់ ពេលកំពុងបំពេញការងារ។ នៅក្នុងអំឡុងពេលជាមួយគ្នានោះដែរ មូលនិធិនេះតាមសេចក្តីរាយការណ៍មកថា បានពិន័យក្រុមហ៊ុនចំនួន ៧ ដែលមិនគោរពតាមបទបញ្ញាត្តិនិងបទបញ្ជារបស់មូលនិធិ ហើយបានប្តឹងក្រុមហ៊ុន ៣ ទៀតទៅតុលាការ។

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន កម្មវិធីរោងចក្រល្អនៅកម្ពុជាបានលើកឡើងពីសុវត្ថិភាពអគ្គីភ័យ ថាជាកង្វល់ពិសេសមួយ។ របាយការណ៍នោះបានកត់សំគាល់ថា ១៥% នៃរោងចក្រដែលត្រូវបានចុះមើលបានចាក់សោរទ្វារក្នុងពេលកម្មករធ្វើការ ហើយមាន ៥៣% មានផ្លូវចេញមានការរាំងខ្ទប់ចេញមិនរួច។ តួលេខនេះផ្ទុះបញ្ចាំងពីការថយចុះនៃការគោរព បើធៀបនឹងឆ្នាំទៅ។

មូលនិធិជាតិផ្នែកសន្តិសុខសង្គមបានរាយការណ៍ថា នៅក្នុងអំឡុងពេល ៦ ខែដំបូង មានកម្មករ-និយោជិតចំនួន ៨៩៦ នាក់បានដួលសន្លប់នៅតាមរោងចក្រចំនួន ១៦ ទូទាំងប្រទេសក្នុងពេលកំពុងបំពេញការងារ ។ គ្មានសេចក្តីរាយការណ៍ពីរបួសធ្ងន់ធ្ងរ ដោយសារការសន្លប់ទេ ។ អ្នកសង្កេតការណ៍និយាយថា ខ្យល់អាកាសចេញចូលមិនល្អ កង្វះអាហារូបត្ថម្ភត្រឹមត្រូវសំរាប់កម្មករ និងចំហាយពុលពីដំណើរការផលិតបានជួយនាំអោយមានកម្មករសន្លប់ច្រើន។